# សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

# KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641


មាតិការឿង

Issue 159 Aug 14th-26th, 2014

**Free**


[illegible] ....០២
[illegible] ....០៤
[illegible] ....០៥
[illegible] ....០៦
[illegible] ....០៧
[illegible] ....១០
[illegible] ....១៤
[illegible] ....២៥



New Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852


# មកលេងឡូវែលរដ្ឋម៉ាសាឈូសេត



Visiting Lowell, Massachusetts

**ដោយ : ពិន សំខុន**

●●●សប្ដាហ៍នេះសហគមន៍ខ្មែរនៅឡូវែលជាពិសេសសហគមន៍ **តទៅទំព័រទី ០២**


## ការិយាល័យ មេធាវី ថំមាស ស្ដាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration • អន្តោប្រវេសន៍
- Auto Crash • គ្រោះថ្នាក់រថយន្ត
- Divorce • លែងលះប្ដីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**

## ការិយាល័យច្បាប់ ហ្វ្រង់ស៊ីស្កូ ជេ.រ៉ូសា



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា



Andrew ´Bunna´ Taing, Esq.
មេធាវី ប៊ុណ្ណា អែនឌ្រូ តាំង

Law Office of:
**FRANCISCO J. ROSA**
ATTORNEY AT LAW

| SERVICES | តំណាងក្ដីដូចខាងក្រោម |
|---|---|
| Auto Accidents/ Personal Injury | គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ |
| Bankruptcy | ក្ស័យធន |
| Immigration | អន្តោប្រវេសន៍ |
| Consumer Protection | ការពារអតិថិជន |
| Real Estate Closings/Disputes | ទំនាស់ផ្នែកអចលនវត្ថុ |
| Divorces Child Custody | លែងលះ និងអាណាព្យាបាលកិច្ច |

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | help@attorneyrosa.com
www.attorneyrosa.com

## VMART LOWELL

ចាប់បើកហើយ !



**ផ្សារម្ហូបអាស៊ី**
មានម្ហូបច្រើនមុខដល់ទៅ ១២,០០០មុខ
សាច់ស្រស់ និងម្ហូបធ្វើហើយ ម្ហូបស្រស់ៗ
មកពីបសស្តុន, ញូយ៉ក, និងគ្រប់កន្លែងទូទាំងប្រទេស
តម្លៃល្អបំផុត ! ស្រស់ថ្មីបំផុត !

អាសយដ្ឋាន **123 Church Street**
**Lowell, MA 01852**
**អតីតផ្សារចាត់ដំបង**

GRAND OPENING
August 1st, 2014




ថ្នាក់ដឹកនាំក្រុងឡូវែល និងតំណាងសភាពាណិជ្ជកម្មចូលរួមអបអរសាទរពិធីសម្ពោធហាងថ្មី

# The History of Southeast Asian Water Festival in Lowell

**By Moniphal Bing, KhmerPost USA Intern**



In the 90s, Lowell was introduced to a new festival called the "Southeast-Asian Water Festival," which it is the second largest festival in Lowell next to the Folk Festival. A primary holiday for the Southeast-Asia region, the Water Festival has been celebrated in multiple countries such as, Cambodia, Laos, Thailand, and Myanmar (Burma,) since the 11th centuries. The origin of the festival has a different story to tell, depend on what country refer to.

For example, starting with the Cambodian history, the Khmer Empire had achieved peace and prosperity following with the victorious naval battle against the Chams. In results, King Jayavarman VII decided to organize the Water Festival with two purposes of selecting a champion of the naval battles, and to train his army to prepare for battle. Throughout times, **Continued to Page 27**



## តមកពីទំព័រទី ១ មកលេងឡូវែលរដ្ឋម៉ាសាឈូសេត...

អាស៊ីអគ្នេយ៍ក្នុងដំបន់កំពុងរៀបចំពិធីបុណ្យអុំទូកប្រចាំឆ្នាំដ៏អធិកអធម្មមួយ នាថ្ងៃទី១៦ សីហា ២០១៤ សម្រាប់ជាឱកាសទទួលភ្ញៀវពីក្រៅដែលរៀងរាល់ឆ្នាំមកកំសាន្តវប្បធម៌អាស៊ីផង និងមកស្គាល់តំបន់ដែលជនជាតិខ្មែរលើកតំកើងវប្បធម៌អាស៊ី បានខ្ពង់ខ្ពស់ជាងគេនាឆ្នេរខាងកើតនៃលេខមុន១៥៨ នូវផែនទីក្រុងខ្មែរដ៏សម្បូរជាងគេដោយហាងពាណិជ្ជកម្មខ្មែរធំតូចភ្ជាប់ទៅនឹងកន្លែងដែលប្រារព្ធអុំទូក ព្រមទាំងរំលឹកពីប្រវត្តិនៃកំណើតសហគមន៍អាស៊ីអគ្នេយ៍គ្រាន់ទុកជាការរៀនសូត្រជាមួយផងដែរ ។

រៀងរាល់ឆ្នាំអុំទូកនៅឡូវែលបានទាក់ទាញ




សហរដ្ឋអាមេរិកនេះផង ។

កាសែតខ្មែរផុសបានផ្ដល់ការចូលរួមយ៉ាងសកម្មក្នុងផ្នែកអភិវឌ្ឍន៍តាមជំនាញនឹងតួនាទីរបស់ខ្លួនដោយបានបោះពុម្ពផ្សាយនៅក្នុងកាសែតភ្ញៀវមកពីជិតឆ្ងាយប្រមាណជា៣-៤ម៉ឺននាក់ (ខ្លះថា៥-៦ម៉ឺននាក់) ឱ្យបានមកលេងបុណ្យយ៉ាងអ៊ូអរ បើទោះជាពីធីអុំទូកអកអំបុកសំពះព្រះខែជាវប្បធម៌ដ៏មាន **តទៅទំព័រទី ១០**

វិភាគនយោបាយខ្មែរ
ដោយ : ពិន សំខុន

# រសជាតិផ្អែម ឬជូ នៃគណបក្សសង្គ្រោះជាតិចូលសភា

## Sweet or Sour As CNRP Entered Cambodia National Assembly?


ពិន សំខុន

សម រង្ស៊ី - កឹម សុខា បានធ្វើអ្វីគ្រប់យ៉ាងឱ្យអាចចូលទៅបោះ ឆ្នោតខែកក្កដា ២០១៣ ដើម្បីចូលសភា ឥឡូវចូលហើយតែយឺត១ឆ្នាំ ហេតុអ្វី ក៏អ្នកគាំទ្រខឹងនឹងកាចូលសភានេះ? តើក្នុង១ឆ្នាំដែលយឺតនេះ គណបក្សសង្គ្រោះជាតិមានខាតពេលវេលារបស់ខ្លួន ឬទេ ?

ក្នុងរយពេល១ឆ្នាំនេះ មេគណបក្សសង្គ្រោះជាតិបានដាក់វិញ្ញាសារដ៏សំខាន់១ដល់ប្រជាជាតិបន្ទាប់ពីឃើញលទ្ធផលប្រកាសដោយគ.ជ.ប.ថាមានបាត់សម្លេងឆ្នោត២០ម៉ឺនសន្លឹក (ប្រភពពីរបាយការឯករាជ្យ) គឺជារស់ជាតិដ៏ផ្អែមសំរាប់គណបក្សប្រឆាំងតែគ្មានទ័ពសម្រាប់ប្រមូលរាស្ត្រម្ចាស់សម្លេង២០ម៉ឺននោះ មកបង្ហាញខ្លួននៅចំពោះមុខពិភពលោកដោយបាតុកម្មអហឹង្សា រហូតដល់បានពលរដ្ឋប្រមាណ១លាននាក់ មកបង្ហាញពីសម្លេងដ៏គួរឱ្យញាក់សាច់របស់ពលរដ្ឋ កាលពីចុងខែធ្នូ២០១៣ ថានេះជាភាពពិតខុសគ្នាពីសម្លេងនៃហិបឆ្នោតគ.ជ.ប.របស់ហ៊ុនសែន។ គណបក្សប្រជាជនរង់ចាំអំពើហិង្សាមួយកើតនៅពេលនោះ តែគណបក្សសង្គ្រោះជាតិមិនបានយកសម្លេងដ៏ខ្លាំងខ្លានោះទៅធ្វើរដ្ឋប្រហារសម្រាប់ដំណែងធ្វើការជំនួសនាយករដ្ឋមន្ត្រី ហ៊ុន សែន ទេ ហើយ នេះជាភាពជូចត់នឹងខកចិត្តដោយគណបក្សប្រជាជនមិនអាចប្រើទាហ៊ានលក់ក្បាលរបស់ខ្លួន សម្រាប់បញ្ចប់ជីវិតគណបក្សប្រឆាំងស្របច្បាប់ បាន ។

**តទៅទំព័រទី ០៨**



# សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក រៀបចំកម្មវិធី ជជែកពិភាក្សាតទល់មុនពេលបោះឆ្នោតជ្រើសរើស តំណាងប្រចាំខណ្ឌមីដជលសិក លេខ១៨

កិច្ចពិភាក្សានេះនឹងធ្វើឡើងនៅថ្ងៃអង្គារ ទី១៩ ខែសីហា ឆ្នាំ២០១៤ វេលាម៉ោង៧យប់ នៅទីស្នាក់ទូរគមនាគមន៍ឡូវែល ឬហៅកាត់ថា អិល ធី ស៊ី ដែលស្ថិតនៅអាស័យដ្ឋាន២៤៦ Market Street ក្នុងក្រុងឡូវែល ។ កិច្ចពិភាក្សានេះ នឹងចាក់ផ្សាយផ្ទាល់ក្នុងទូរទស្សន៍ខ្សែកាបឡូវែល និងផ្សាយបន្តផ្ទាល់នៅលើគេហទំព័រ www.ltc.org ។

ខណ្ឌមីដជលសិកលេខ១៨ មានវិសាលភាពដោយរាប់ទាំង អេកឃឺ និង ហៃឡែន នៃក្រុងឡូវែលផងដែរ ។

បេក្ខជនទាំងប្រាំរូបដែលកំពុងឈរឈ្មោះសម្រាប់ការបោះឆ្នោតបឋម មាន ប្រាយអិន ដូណូវាន (Brian Donovan) ចេមស៍ លារី (James Leary) រ៉ាឌី ម៉ម (Rady Mom) ដេវីដ អ៊ូលេត (David Ouellette) និង ផល រដ្ឋា យ៉ែម (Paul Ratha Yem) ។

សម្រាប់ព័ត៌មានបន្ថែមអំពីកិច្ចពិភាក្សា សូមទាក់ទង **សុបិន្ត ពិន** សហអគ្គនាយកគ្រប់គ្រង: អ៊ីម៉ែល sobenpin@khmerpost.us ឬ តាមទូរស័ព្ទ **978-656-8141** (ទូរស័ព្ទដៃ) ឬ **978-677-7163**(ការិយាល័យ)

# PRESS RELEASE

## KhmerPost USA to Host State Representative Debate

The KhmerPost USA will host a debate for the candidates for the Democratic nomination for the 18th Middlesex Representative District on Tuesday, August 19, 2014 at 7:00 p.m. at Lowell Telecommunications Corporation at 246 Market Street in Lowell. The debate will be televised live on Lowell cable TV and will be streamed live on www.ltc.org.

The 18th Middlesex District includes the Acre and Highlands neighborhoods of Lowell. The seat was previously held by Kevin Murphy who resigned earlier this year when he was elected Lowell City Manager.

**Candidates in the Democratic Primary are Brian Donovan, James Leary, Rady Mom, David Ouellette and Paul Ratha Yem.**


JimLeary


DaveOuellette


Paul Ratha Yem


Brian Donovan


Rady Mom

The KhmerPost USA is a community newspaper published biweekly in Lowell, Massachusetts and distributed in Cambodian-American communities throughout the East Coast of the United States. Founded in 2008 by Roger Samkhon Pin, the former President of the Cambodian Journalist Association of Cambodia (1994-1997) and the former Director of Radio Free Asia's Cambodian Services.

For more information about the debate, contact Soben Pin, Managing Partner of KhmerPost USA via email sobenpin@khmerpost.us or direct number at **978-656-8141 (cell) | 978-677-7163 (office)**

# ពហិការនៅផ្សារម៉ាឃីតបាសឃីត

# Boycott at Market Basket 2

**ដោយ : ខ្មែរផុស ស.រ.អា.**

**ឡូវែល:** កាលពីលេខមុនយើងបានចុះផ្សាយពីករណីពហិការរបស់កម្មករផ្សារដ៏ធំមួយនៅម៉ាសាឈូសែតឈ្មោះម៉ាឃីតបាសឃីតបានតវ៉ាជិត១ខែហើយឱ្យប្តូរម្ចាស់ហាងថ្មីអទ័រអេសដែលបានឡើងកាន់ដំណែងដោយសារបានទទួលភាគហ៊ុនលើស៥០ភាគរយចេញ ហើយទាមទារឱ្យដាក់ម្ចាស់ហាងពីមុនអទ័រធីនោះមកវិញ។ ផ្សារម៉ាឃីតបាស ឃីត ជាផ្សារលក់ម្ហូបអាហារដ៏ធំមួយនៅរដ្ឋម៉ាសាឈូសែតមានហាង៧១ ល្បីឈ្មោះដោយលក់ម្ហូបអាហារមានគុណភាពខ្ពស់ ហើយរក្សាតម្លៃបានថោកជាងផ្សារឯទៀត១បានផង ដូចជាប្រជែងជាមួយផ្សារហានាហ្វតមានហាង១៨០នៅញូអែនគ្លីនជាដើម ។

ហេតុអ្វីក៏កម្មករធ្វើបាតុកម្មប្រឆាំងនឹងម្ចាស់ហាងជាចៅហ្វាយដែលមិនទាន់បានធ្វើអ្វីខុសនៅឡើយ? នៅពេលដែលម្ចាស់ហាងថ្មីឡើងជាប្រធានមានគម្រោងមួយបានលេចឮដល់ក្រុមកម្មករថាអ្នកកាន់ដំណែងថ្មីនេះ មានបំណងតំឡើងថ្លៃទំនិញដើម្បីឱ្យប្រាក់ចំណេញច្រើនសម្រាប់ចែកជូនម្ចាស់ហ៊ុននឹងកាត់បន្ថយគុណភាពបុព្វសិទ្ធកម្មករដែលធ្លាប់ទទួលឃើញបំណងធ្វើយ៉ាងនេះកម្មករយល់ថា ខ្លួនដែលជាភ្ញៀវទិញម្ហូបពីផ្សារម៉ាឃីតបាសឃីតដែរនោះ នឹងទិញម្ហូបអាហារខ្លួនថ្លៃជាងមុនរួមនឹងការបាត់បង់បុព្វសិទ្ធខ្លះថែមទៀតនោះក៏ផ្ទុះជាបាតុកម្មឡើង ។






**តើពហិការកម្មករទៅដល់ទីណាហើយ?**

ម្ចាស់ហាងម៉ាឃីតបាសឃីតមានបំណងនឹងបញ្ឈប់ការងារនឹងមិនឱ្យប្រាក់ខែកម្មករដែលតវ៉ានោះថែមទៀត តែក្រសួងការងារមិនអនុញ្ញាត្តិ។ ជិត១ខែមកហើយ កូដករបង្ហាញការប្រឆាំងគ្រប់ទីកន្លែងធ្វើឱ្យផ្សារម៉ាជីតបាសឃីតគាំងដំណើរគ្មានភ្ញៀវចូលទិញធ្វើឱ្យកម្មករដែលមិនតវ៉ានៅធ្វើការនៅឡើយត្រូវគេបញ្ឈប់ពីកាងារដដែល។ ម្ចាស់ហាងចាស់ក៏បានស្នើទិញភាគហ៊ុនពីអ្នកថ្មីឱ្យបានភាគច្រើន ដើម្បីអាចត្រឡប់មកកាន់ការណ៍វិញ តែពេលនេះមិនទាន់បានសម្រេចនៅឡើយទេ។ នាពេលនេះហាងប្រជែងហានាហ្វតបានស្នើទិញភាគហ៊ុនអទ័រអេស ឬក៏ហាងទាំងមូលក៏បានតែអាទ័ធីបានប្រកែកមិនព្រមលក់ភាគហ៊ុនរបស់ខ្លួនរួចហើយ។

លោកអភិបាលរដ្ឋ ប៉ាទ្រីក ឌូវ៉ល បានចេញសេចក្តីថ្លែងការណ៍មួយថា លោកមានកង្វល់ចំពោះសុខុមាលភាពរបស់ពលរដ្ឋទាក់ទងទៅនឹងជម្លោះនៅផ្សារ ម៉ាឃិតបាឃីត នឹងហើយចង់ឃើញដំណោះស្រាយឱយបានឆាប់រហ័សកូដករចូលធ្វើការវិញ នឹងភ្ញៀវអាចត្រឡប់ទៅទិញម្ហូបអាហារខ្លួនវិញបាន ។

"Market Basket is a proud company and well-respected brand in the Commonwealth that employs thousands of good people. As governor and as a citizen, I want the company to continue to thrive, for the benefit of customers, workers and the general economy. By any measure, the disruption that followed your recent chance in CEO has gotten out of hand, and I am writing to urge you to find a prompt resolution". **MA Governor**




**CONWAY**
**INSURANCE AGENCY**

**រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។**

**យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :**

**ការធានារ៉ាប់រងគ្រួសារ**
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បះ
- វត្ថុបុរាណ

**ការធានារ៉ាប់រងជំនួញ**
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខ័ខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេង១ទៀត

77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
**សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង**

**ឱសថស្ថាន ស៊ីសាយដ៍**
**SEASIDE PHARMACY**
169 Shirley Ave Revere, MA
**(781) 284-6525**




- និយាយដោយផ្ទាល់ទៅកាន់ឱសថការី
- បញ្ជូនដល់គេហដ្ឋានបើចាំបាច់
- ទទួលប័ណ្ណធានារ៉ាប់រងម៉ាស់ហៀល និងប័ណ្ណធានារ៉ាប់រងផ្សេងទៀត
- អាចបន្ថែមឡើងវិញនូវវេជ្ជបញ្ជាទាំងអស់ក្នុងពេលតែមួយ
- ផលិតផលនិងសម្ភារៈមាននៅបញ្ជរតាំង
- ងាយស្រួលបញ្ជូន សូមនាំយកនូវដបថ្នាំរបស់លោកអ្នក យើងខ្ញុំជួយចាត់ចែងឱ្យ



**ផ្ទេរនូវវេជ្ជបញ្ជារបស់លោកអ្នក ហើយទទួលបាននូវវីតាមីនមួយកំប៉ុងជារៀងរាល់ខែ**

# តួនាទីរបស់តំណាងរដ្ឋ
## The Job of a State Representative


Richard Howe

**ដោយ : ឪក ហាវ**

នៅខែកញ្ញា ២០១៤នឹងមានធ្វើការបោះឆ្នោតជុំទី១ ដើម្បីជ្រើសរើសបេក្ខជនតំណាងរដ្ឋខាងគណបក្សប្រជាធិបតេយ្យ ដែលនឹងទទួលសម្លេងឆ្នោតច្រើនជាងគេទៅប្រជែងនឹងបេក្ខជនខាងគណបក្សសាធារណរដ្ឋ នៅជុំទី២ នាខែវិច្ឆិកាបន្ទាប់មក។ ក្នុងចំណោមបេក្ខជន៥រូបដែលឈរឈ្មោះមានខ្មែរ២រូបដែលចូលប្រជែងសម្រាប់អាសនៈតែមួយនៅសង្កាត់លេខ១៨នៃក្រុងឡូវែល។ ឪក ហាវ នឹងនិយាយអំពីតួនាទីរបស់តំណាងរដ្ឋថា ជាអ្នកធ្វើច្បាប់នឹងស្តាប់បញ្ហាប្រជាពលរដ្ឋក្នុងសង្កាត់របស់ខ្លួនយកទៅដោះស្រាយ...

*សូមអានជាបន្តជាភាសាអង់គ្លេសដូចតទៅ :*

The Massachusetts State Legislature consists of two houses: the Senate and the House of Representatives. There are 40 State Senators and 160 State Representatives. Lowell has one state senate district (represented by Eileen Donoghue) and three state representative districts (represented by Thomas Golden and David Nangle). The third district, known as the 18th Middlesex, was represented by Kevin Murphy until he became City Manager so voters of the Highlands and the Acre will elect a new representative for that district this fall.

The most important responsibility of a state representative is to make laws. All state laws, from the speed limit on highways to how much you pay in state taxes, are made by state representatives and state senators. A proposed law is called a bill. Any state representative may "file" or present a bill to the entire legislature but a bill only becomes law when it receives the support of a majority of state senators and state representatives.

Another important responsibility of a state representative is to listen to the opinions of the people who live in the state representative district and to assist those people when they need help. Anyone who has a problem with almost any issue should speak with his or her state representative about the it.

When electing a state representative it is important to select someone with good judgment, who is easy to talk to, and who understands the problems people in the district face every day.

Khmer Owned & Operated

The Joint Commission National Quality Approval

Independence Home Care
Health Services LLC

ថែរក្សាសុខភាពដល់លំនៅដ្ឋានរបស់អ្នកទូទាំងរដ្ឋ

**Licensed Home Care Provider / Companion Services**

Certified Medicare/Medicaid • Joint Commission Accreditation • Home Nursing Care Provider Licensed by RI Department of Health

**Approved Provider of All State Programs:** Department of Elderly Affairs / Department of Human Services

**Skilled Nursing**
- Registered Nurses
- Home Health Aide
- Physical Therapy
- Occupational Therapy
- Speech Therapy
- Medical Social Worker

**Unskilled Nursing**
- Companionship
- Personal Care
- Bathing
- Dressing
- Safety
- Meal Preparation and Housekeeping
- Medication Reminders
- Errands and Assistance with Transportation

**Employment**
**Nurses & CNAs**
- Helping Over 100 Rhode Island Elderly Southeast Asians
- We Employ Over 50 Southeast Asians
- FREE ASSESMENT




*Let our family, take care of yours.*



**CALL US TODAY!**
**(401) 437-8337**
www.independencehs.com
Available 24/7

1179 Elmwood Ave.
Providence, RI 02907

- See our Khmer Video about Home Care at our website -

# ផ្លាស់ប្តូរអាស័យដ្ឋានបោះឆ្នោតនៅឡូវែល

# Change of Voting Locations in Lowell

By Richard Howe, Jr.

គណៈកម្មការរៀបចំការបោះឆ្នោតនៅឡូវែលបានធ្វើការផ្លាស់ប្តូរអាស័យដ្ឋាននៃទីកន្លែងដែលត្រូវបោះឆ្នោតសម្រាប់ទីតាំងចំនួន ១២ ដែលមានក្នុងសេចក្តីពិស្តារខាងក្រោម។ ការផ្លាស់ប្តូរទីតាំងបោះឆ្នោតនេះ ធ្វើឡើងសម្រាប់ការបោះឆ្នោតថ្នាក់រដ្ឋជាបឋម ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអង្គារ ទី៩ កញ្ញា ២០១៤ និងសម្រាប់ការបោះឆ្នោតនៅថ្ងៃអង្គារទី៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ព្រមទាំងសម្រាប់ការបោះឆ្នោតនាឆ្នាំខាងមុខ។ ខាងក្រោមនេះ គឺជាបញ្ជីឈ្មោះទីកន្លែងបោះឆ្នោតចាស់ និងថ្មី។

The Lowell Election Commission has changed the location of many of the voting places in Lowell. The new places will be used for the State Primary Election on Tuesday, September 9, 2014; at the State Election on Tuesday, November 4, 2014 and at all elections in future years. Here is a list of each voting precinct in the city with the old voting place and the new voting place.

**ខណ្ឌទី១, សង្កាត់ទី ១**

Ward 1, Precinct 1 ទីតាំងចាស់ Old: Firehouse on High Stទីតាំងថ្មី New: Father Norton Manor, Lowell Housing Authority, 137 High St

**ខណ្ឌទី១, សង្កាត់ទី ២**

Ward 1, Precinct 2 ទីតាំងចាស់ Old: Reilly School on Douglas Rd - no change

**ខណ្ឌទី១, សង្កាត់ទី៣**

Ward 1, Precinct 3 ទីតាំងចាស់ Old: Reilly School on Douglas Rd – no change

**ខណ្ឌទី២, សង្កាត់ទី ១**

Ward 2, Precinct 1 ទីតាំងចាស់ Old: Tsongas CenterTItaMgfμI New: Pollard Memorial Library at 401 Merrimack St

**ខណ្ឌទី២, សង្កាត់ទី ២**

Ward 2, Precinct 2 ទីតាំងចាស់ Old: Tsongas CenterTItaMgfμI New: Lowell Telecommunications Corp, 246 Market St

**ខណ្ឌទី១, សង្កាត់ទី ៣**

Ward 2, Precinct 3 ទីតាំងចាស់ Old: Tsongas Center ទីតាំងថ្មី New: New: Lowell Telecommunications Corp, 246 Market St

**ខណ្ឌទី៣, សង្កាត់ទី ១**

Ward 3, Precinct 1 ទីតាំងចាស់ Old: Bailey School on Campbell Dr – no change

**ខណ្ឌទី៣, សង្កាត់ទី ២**

Ward 3, Precinct ២ទីតាំងចាស់ Old: Bailey School on Campbell Dr – no change

**ខណ្ឌទី៣, សង្កាត់ទី ៣**

Ward 3, Precinct 3 ទីតាំងចាស់ Old: Morey School on Pine St – no change

**ខណ្ឌទី៤, សង្កាត់ទី១**

Ward 4, Precinct 1 ទីតាំងចាស់ Old: Morey School on Pine St – no change

**ខណ្ឌទី៤, សង្កាត់ទី ២**

Ward 4, Precinct 2 ទីតាំងចាស់ Old: VFW on Plain St ទីតាំងថ្មី New: Flanagan Development, Lowell Housing Authority, 580 Chelmsford St

**ខណ្ឌទី៤, សង្កាត់ទី៣**

Ward 4, Precinct 3 ទីតាំងចាស់ Old: Rogers School on Highland St – no change

**ខណ្ឌទី៥, សង្កាត់ទី១**

Ward 5, Precinct 1 ទីតាំងចាស់ Old: McAvinnue School on Mammoth Rd – no change ខណ្ឌទី៥, សង្កាត់ទី ២

Ward 5, Precinct 2 ទីតាំងចាស់ Old: Polish American Veterans Hall on Coburn StTItaMgfμI New: Fr Morrissette Manor, Lowell Housing Authority, 111 Hildreth St

**ខណ្ឌទី៥, សង្កាត់ទី៣**

Ward 5, Precinct 3 ទីតាំងចាស់ Old: Greenhalge School on Ennell St – no change តទៅទំព័រទី១១


GATEWAY FAMILY DENTAL

www.gatewayfamilydental.com • (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)



DR. SERENA B. CHUOP

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 13 years, she has been in private practices providing all aspects of General Dentistry. Her state of the art dental practice includes digital x-rays, paperless patient chart system, and new dental equipments.




WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉ែរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

Free Teeth Whitening Kit

(with new patient´s x-ray, exam, cleaning at regular price)

MOST DENTAL INSURANCES ACCEPTED

INCLUDING MASSHEALTH

FINANCING AVALIABLE

យើងទទួលនូវគ្រប់ អ៊ិន ស៊ូរ៉ែន

Masshealth

យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ

CALL FOR YOUR FREE CONSULTATION

(978) 455-5044

# ប្តូរចរាចរជាផ្លូវទៅមកក្នុងក្រុងឡូវែល

# Two Way Traffic in Downtown Lowell

**ដោយ : ឌីក ហាវ**

ផ្លូវនៅកណ្តាលក្រុងមួយចំនួនដែលជាផ្លូវទៅទិសតែមួយចំនួនតាំងពី៥០ឆ្នាំមក ហើយនឹងក្លាយជាផ្លូវទៅ-មកវិញនាកណ្តាលក្រុងឡូវែល ចាប់តាំងពីថ្ងៃប្រារព្ធពិធីអុំទូកថ្ងៃទី១៦ សីហា ២០១៤នេះទៅហើយ ។

*សូមអានអត្ថបទ ឌីក ហាវ ជាភាសាអង់គ្លេស ។*

On Saturday, August 16, 2014 (the same day as the Water Festival), anyone driving through downtown Lowell will notice a big change. The network of one way streets that has been in place for more than fifty years will become two way. Here are the streets that will change :

**តទៅទំព័រទី ១១**





សាលាថែទាំកុមារឡូវែល

LOWELL DAY NURSERY ASSOCIATION

119 HALL STREET
LOWELL, MASS.01854
978-454-5981

- កំពុងបើកទទួលសិស្សានុសិស្សកុមារអាយុ១៥ខែ រហូតដល់២ឆ្នាំ៩ខែ
- សាលាមុនថ្នាក់មតេយ្យ
- មានបុគ្គលិកប្រកបគរុកោសល្យល្អ
- ជាសាលាល្អចំណាត់ថ្នាក់ប្រចាំឆ្នាំ

- OPENINGS AVAILABLE! TODDLERS -15 MONTHS THRU 2YEARS 9 MONTHS
- PRESCHOOL AND KINDERGARTEN
- GREAT CURRICULUM WITH SEASONED STAFF
- NATIONAL DIRECTOR OF THE YEAR

www.lowelldaynursery.com
or Like us on Facebook – Lowell Day Nursery Association










Navi Osorno
SENIOR LOAN OFFICER
EMAIL: navi.osorno@jdcu.com
OFFICE: 978-323-4722
CELL: 978-427-7302
NMLS #: 454804

Meet Navi Osorno, fluent in Khmer and mortgages.

Jeanne D'Arc speaks your language. When you need to talk to someone who's knowledgeable and experienced about home-buying, we're here, keeping the process simple and straightforward.

Jeanne D'Arc offers you these mortgage advantages:

- No Cost, No Obligation Pre-Approvals
- Our First-Time Home Buyer Programs
- Unique Construction Mortgage Loans
- No Closing Cost Mortgage Options
- Refinancing Your Mortgage To A Lower Rate, Shorter Term Or To Take Cash Out
- Loans For Members With Less-Than-Perfect Credit
- Avoiding Private Mortgage Insurance (PMI) With Less Than 20% Down
- Navi Can Meet You When It's Convenient For You

CONTACT NAVI OSORNO TODAY AND LET'S GET YOU STARTED.

JEANNE D'ARC CREDIT UNION
*we share a common thread*
978-452-5001 | JDCU.COM
LOWELL | DRACUT | CHELMSFORD | TYNGSBORO | METHUEN | WESTFORD

Federally insured by NCUA | Shares and Deposits in excess of NCUA limits are fully insured by MSIC. | Equal Opportunity Lender
Jeanne D'Arc Credit Union and the phrase We Share a Common Thread are federally registered trademarks owned by Jeanne D'Arc Credit Union.

## តមកទំព័រទី ០២ រសជាតិផ្អែម ឬជូនៃគណបក្សសង្គ្រោះជាតិ...

តែចាប់តាំងពីខែមករា ឆ្នាំ២០១៤ មក
ទល់ពេលនេះ មេដឹកនាំគណបក្សសង្គ្រោះជាតិ
បានងាកមករកទិសដៅនយោបាយវិញម្តង គឺ
កែប្រែកម្លាំងនៃអំណាចក្បាលម៉ាស៊ីនរដ្ឋនឹង
តម្លើងឥទ្ធិពលសមាជិកបក្សឱ្យមានអំណាចរដ្ឋក្នុង
ក្បាលម៉ាស៊ីននោះវិញម្តង គឺការបញ្ចូលសភា
នៃសមាជិកបក្សប្រឆាំងមែនទែនចំនួន៥៥នាក់

នៅក្នុងសភាជាតិដែលមានគ្នា១២៣រូប ។
គណបក្សប្រជាជនបានរង់ចាំបក្សប្រឆាំងចូលសភា
ម្តងទៀត ដើម្បីធ្វើឱ្យម៉ាស៊ីនរដ្ឋរបស់ខ្លួនឈប់
គាំងផង នឹងបំបែកពីអ្នកគាំទ្រសង្គ្រោះជាតិផង
ប៉ុន្តែអ្នកគាំទ្រនោះ បានត្រូវបំបែកពីគណបក្សរួច
ជាស្រេចតាំងពីខែមករាមកម្លេះ បើទោះជាបែក
គ្នាពីសង្គ្រោះជាតិក៏មិនបែកពីឯកភាពនៃក្រុម
របស់ខ្លួនឡើយ ភាពស្នេហាជាតិរបស់ពលរដ្ឋ
ពេលនេះ មានភាពរឹងមាំណាស់នឹងមានសមត្ថភាព
គ្រប់គ្រាន់នឹងជ្រើសរើសថា នរណាជាមេដឹកនាំ
ពិតប្រាកដរបស់ខ្លួនថែមទៀតនេះក៏ជាបំណងនៃ
គណបក្សសង្គ្រោះជាតិដែរ ។

ហេតុអ្វីក៏មានប្រជាពលរដ្ឋជាច្រើនខឹងនឹង
គណបក្សសង្គ្រោះជាតិចូលសភា? គឺភាពក្រីក្រ
គឺការបាត់បង់បូរណភាពទឹកដី គឺកលល្បិចមិន
ចេះចប់របស់អតីតខ្មែរក្រហមដែលប្រជារាស្ត្រ
ចង់បញ្ចប់យ៉ាងឆាប់រហ័សតែគណបក្សសង្គ្រោះជាតិ
មិនអាចផ្តល់រដ្ឋប្រហារលើរដ្ឋបាល ហ៊ុន សែន
បានកាលពីឱកាសប្រមូលបុំបាតុករខ្មែរដ៏ធំបំផុត
នៃប្រវត្តនយោបាយកម្ពុជា នាថ្ងៃ២៩ ធ្នូ២០១៣
បាននោះ ម្លោះហើយនៅលើពាក្យស្លោកថា ដូរ
ឬមិនដូ? ចម្លើយថា ដូរនោះ មិនមែនដោយរដ្ឋ
ប្រហារទេ គឺដោយការឆែកហិបឆ្នោត ឬក៏
បោះឆ្នោតសារជាថ្មីភ្លាមតែប៉ុណ្ណោះដែលជាអន្ទាក់
ម្យ៉ាងដ៏ជូចត់សម្រាប់គណបក្សប្រជាជនដែល
ត្រូវតែបង្ហាញមុខអាក្រក់របស់ខ្លួន ថាជាចោរ
លួចឆ្នោតដោយមិនអាចបង្ហាញភស្តុតាងនៃលទ្ធ
ផលឈ្នះរបស់ខ្លួនបាន ។ ដោយសារតែភាពចេះ
ដឹងនឹងស្មារតីកាន់វាស្នាជាតិដោយខ្លួនឯងនេះ
ហើយ ដែលពលរដ្ឋសង្ស័យថា គណបក្សសង្គ្រោះ
ជាតិចូលសភាដោយសារតែចង់បានងារជាឯកឧត្តម
តែប៉ុណ្ណោះ បើវាយរំលំ ហ៊ុន សែន តែម្តងទៅ
ជាកាស្រេចតែអំពើនេះរហ័សមែនមិនប្រាកដជា
មានជោគជ័យលើជំនាញរបស់ ហ៊ុន សែន នោះ
ទេ ហើយអាចខូចខាតច្រើនទៀតផង ។ បើគណ
បក្សសង្គ្រោះជាតិរៀបចំបានល្អពន្យាពេលដូរបន្តិច
ក៏មិនទាស់អ្វីដែរ ពីព្រោះមិនទាន់ចាំបាច់នឹងប្តូរ
ជីវិតនៅឡើយទេ ដែលសំខាន់នោះ គឺសមាជិក
បក្សប្រឆាំងនៅរក្សាស្មារតីស្នេហាជាតិមិនលក់
ខ្លួននៅជាមួយមេដឹកនាំរបស់ខ្លួនដោយជំនឿ
ខ្ពង់ខ្ពស់ដដែលអ្វីៗនឹងត្រឡប់មកវិញ ។

**តើចូលសភានេះខាត ឬចំណេញ?** មិនមែន
ជាពេលរកស៊ីទេ គឺការស្វែងរកគុណភាពនៃរបប
គ្រប់គ្រងមួយដែលត្រឹមត្រូវបានយូរអង្វែងដោយ
មិនអាចប្រថុយប្រហានមិនអាចខាត ឬចំណេញ
បានទេ ។ គណបក្សសង្គ្រោះជាតិកំពុងមានជោគ
ជ័យក្នុងដំណើរជួសជុលផ្លូវប្រជាធិបតេយ្យមួយ
ដែលខូចខាតដោយរបបប្រជាធិបតេយ្យក្លែងក្លាយ
ពីមុនៗមកបន្ទាប់ពីអ.ស.ប.ក៏សាងផ្លូវដ៏ត្រឹមត្រូវ
នេះ ទុកឱ្យខ្មែរកាលពីឆ្នាំ១៩៩៣មក ។

ខ្ញុំជឿថា ការថ្លែងសសើររបស់លោក បាន
គីមូន អគ្គលេខាធិការនៃអ.ស.ប.ពីដំណោះស្រាយ
សន្តិភាពនៃចូលសភារបស់គណបក្សសង្គ្រោះ
ជាតិមិនមែនធ្វើឱ្យរួចតែពីមាត់នោះទេ គឺជាវត្ថុ
បំណងពិតនៃក្តីសង្ឃឹមដ៏កក់ក្តៅក្នុងការជួសជុល
ផ្លូវប្រជាធិបតេយ្យខ្មែរឡើងវិញនោះហើយ
ជាពិសេសជាការកោតសសើដល់ពលរដ្ឋខ្មែរ
មានសម្បជញ្ញខ្ពស់ជាងរាស្ត្រខ្មែរពេលណាទាំង
អស់ដែលនាពេលនេះ ត្រូវការអ្នកដឹកនាំសុច្ចរិត
យុត្តិធម៌ស្នេហាជាតិរបស់ខ្លួន ហើយជំរើសមាន
តែមួយ គឺគណបក្សសង្គ្រោះជាតិ ។ នាមួយឆ្នាំ
ចុងក្រោយនេះ បង្ហាញទិស្ស័យត្រូវការគ្នាទៅ
វិញទៅមករវាងពលរដ្ឋខ្មែរនឹងគណបក្សសង្គ្រោះ
ជាតិមិនបែកគ្នាបានទេ ៕







Better Products, Better Service
A community bank

| | Washington SAVINGS BANK We give you more | Big Banks |
|---|---|---|
| ATMs | 60,000 Nationwide free ATMs | Much Less! |
| Free Checking | YES! | Are you kidding? |
| Online Banking | Everything the 'Big Banks' have: Online banking, Bill payment, mobile banking, mobile deposit | We'll give them this one, they have it too |
| Free Designer Debit Card | YES, OVER 80 DESIGNS! | They are not that creative |
| Unlimited Debit Card Cash Rewards | YES! Anytime, Anywhere | No |
| Customer Service | Friendly local people who really want to help solve problems | One word "Voicemail" |
| Lending | Local decisions, by local people who sincerely want to work with you. Your place or ours, day, evening or weekend | See above |
| Bank Headquarters | Lowell, MA - your money and loan payments stay in your community | Canada, Spain Scotland, North Carolina |

"I switched from a large bank several years ago and have never regretted it. This is a small town bank with large bank benefits and far superior service than you get at the larger banks." - Joe S."

"I recently switched from Bank of America and love it here. Should have done it sooner!" – Kelly P.



PLUS RECEIVE A FREE

**kindle fire®**

- Monthly Direct Deposit of at least $1,000
- At least one monthly automatic payment
- An active debit card

Washington SAVINGS BANK
We give you more

washingtonsavings.com

**978-458-7999**

Member FDIC/ Member DIF / Equal Housing Lender

See reverse side for terms and conditions

តមកពីទំព័រទី ៤

## មកលេងឡូវែលរដ្ឋម៉ាសាឈូសេត...

ប្រជាប្រិយនៅកម្ពុជាបានក្លាយមកត្រឹមតែជាការអុំទូកប្រណាំងខ្មែរ ឬអាស៊ីក៏ដោយ ក៏ជាឱកាសប្រមូលផ្តុំជួបជុំបងប្អូនគ្រួសារមិត្តភ័ក្រ្តដ៏សំខាន់មួយនៃអតីតជនភៀសខ្លួនអាស៊ីអាគ្នេយ៍ដ៏ធំជាងគេបង្អស់ប្រចាំឆ្នាំ នាឆ្នេរខាងកើតនៃសហរដ្ឋអាមេរិកដែរ។ ក្នុងពេលនោះ គឺរៀងរាល់ពាក់កណ្តាលខែសីហា នៅលើដងទន្លេ មែរីម៉ាក ត្រង់កន្លែងទំនប់ទឹកធ្លាក់មនុស្សប្រជ្រៀតគ្នាប្រមាណ៣ម៉ាយល៍នៅតាមដងផ្លូវផទូខេតមកមើលតូបរាប់រយដែលបានចែកជូនឱ្យអ្នកបំរើសហគមន៍ឱ្យអ្នករកស៊ីក្នុងតំបន់ឱ្យសិល្បករក្រុមសាសនាខ្មែរ ឡាវ ថៃ ចិន វៀតណាម ភូមា ឥណ្ឌា ដើម្បីមកតាំងបង្ហាញផលិតផល ឬស្នាដៃជំនាញវត្ថុអនុស្សាវរីយ៍ដំណាំក្នុងផើង ម្ហូបចំណី អាស៊ី តំន្ទូរ ចម្លាក់ សំលៀកបំពាក់ មានទាំងរបាំ ភ្លេង ចម្រៀងចម្រុះសាសន៍របស់ខ្លួនទៀតផង។ គេនៅចាំនៅឡើយថា ក្រោមកំដៅហុយៗជិត១០០អង្សាF ជនជាតិអាស៊ីភាគច្រើន ច្រើនជាងគេគឺខ្មែរលាយឡំនឹងអាមេរិកាំងទាំងសទាំងខ្មៅនាំកូនចៅមកកំសាន្តពេញមួយថ្ងៃស្ទើររកដីអង្គុយភ្លក់ម្ហូបអាហារគ្មានធាតុអាកាសក្តៅរបៀបនេះ នាំឱ្យគេចងចាំនូវទឹកត្រជាក់ផឹកមិនចេះឆ្អែតផឹកទឹកអំពៅកិនថ្មីៗដ៏កំពុងមានប្រជាប្រិយ ទោះជាបន្តរកន្ទុយចាំយ៉ាងវែងក៏មិនខ្ជិលក្មេងស្លៀកពាក់តាមរបៀបខ្លីខើចបញ្ចេញសាច់ដូចនៅមាត់សមុទ្រយុវជនជាច្រើនបង្ហាញម្ហូតឈាម រាវ ខោធ្លាក់ក្តិត មានសាក់ពេញខ្លួនពាក់ម្ជុក ពាក់ក្រវិលច្រមុះពាក់ម្ជុកបញ្ចិតទៅក្រោយគួរឱ្យខ្លាច ព្រោះរាងដូចជាក្រុមក្មេងតែរពុករទេះនាំកូនដើរកំសាន្តឱ្យស្គាល់វប្បធម៌ខ្លួនឯង ដូចជាបំណងនៃឪពុកម្តាយចម្មតាដែរ... ចាស់ៗរមទម្យច្រើនមានទម្លាប់ប្រើខោសំពត់អាវបូរាណ ដើរជូតញើសកាត់ ក្លិនផ្សែងសាច់ ឬពោតអាំងឈ្ងុយផ្លែកៗគ្នាធ្វើឱ្យគេដឹងបានថា ក្លិនណាមួយជាម្ហូបចំណូលចិត្តរបស់ខ្លួន... ថ្ងៃនោះក្រុមពាណិជ្ជករដឹងថា នឹងលក់ដាច់ណាស់អាចរាប់ថាជាចំណូលដ៏សំខាន់បំផុតប្រចាំឆ្នាំបាន ម្លោះហើយរៀបចំខ្លួននាំក្រុមគ្រួសារមកជួយបំរើច្រើនគ្នានឹងប្រើពាក្យភាសារពិរោះ គួរសមដាក់ភ្ញៀវ គួរឱ្យចង់ចូលជជែកគ្នាលេងផង។


អនុស្សាវរីយ៍អុំទូកឆ្នាំ២០១៣

គណកម្មការរៀបចំបុណ្យអុំទូកកាលពីឆ្នាំដំបូងៗសម្បូរខ្មែរចូលរួមដុតដៃដុតជើងណាស់ តែដល់ក្រោយមកក៏ក្លាយទៅជាពីធីបុណ្យជនជាតិអាស៊ីអគ្នេយ៍ដែលក្នុងនោះ មានគណកម្មការចម្រុះសាសន៍ដឹកនាំបច្ចុប្បន្នដោយខ្មែរជាប្រធានមានឈ្មោះ វ៉ែន ពេជ្រ បានរៀបចំទទួលភ្ញៀវដោយគ្មានខ្ចះចន្លោះ តាំងពីប្រណាំងទូកតាំងពីពណិផលិតផលជនជាតិអាស៊ីនឹងផលិតផលបំរើសហ-គមន៍តាមតូបកម្មវិធីបង្ហាញវប្បធម៌សហគមន៍រៀបចំសន្តិសុខ ។ល។ ករណីរបៀបនេះ ធ្វើឱ្យបណ្តាជនជាតិអាស៊ីក្នុងតំបន់ស្គាល់គ្នាកាន់តែប្រសើរដោយធ្វើការងាររួមកាន់តែច្រើន រីឯភ្ញៀវដែលមកពីតំបន់ជុំវិញ ឬឆ្ងាយៗក៏កាន់តែស្គាល់ឡូវែលរឹតតែច្បាស់ឡើងដែរ ។ រូបភាពអធឹកអធ៍មនៃពិធីបុណ្យអុំទូកអាស៊ីអគ្នេយ៍បង្ហាញឱ្យឃើញថាសហគមន៍អាស៊ីបានចូលរួមអភិវឌ្ឍន៍សហគមន៍នឹងតំបន់ដែលខ្លួនរស់នៅបានយ៉ាងថ្លៃថ្នូរ។ យ៉ាងណាមិញប្រជាពលរដ្ឋខ្មែរដែលមករស់នៅឡូវែលនេះតាំងពីជាង៣០ឆ្នាំមកហើយបានរីកសុះសាយរហូតដល់បង្កើតបានជាក្រុងខ្មែរផ្តើមឡើងពីតំបន់ដែលខ្មែរឱ្យឈ្មោះខ្លួនឯងថា ផ្សារប៉ៃលិនដែលឋិតនៅក្នុងបរិវេណចន្លោះផ្លូវ មីដលសិច រហូតដល់ផ្លូវ ឆែមស្វត កាត់តាមផ្លូវវេសហ្វតមានហាងលក់ទំនិញធំៗមានអាហារដ្ឋានខ្មែរល្បីឈ្មោះច្រើនមានជាងសំណង់មានកន្លែងកែរសម្ផស្សមានបណ្តាគារដែលបង្ហាញពីសោភណ្ឌភាពវប្បធម៌អាស៊ីមួយទៀត ដែលប្លែកពីឆាយណាថោនដាច់គ្នាស្រឡះតែម្តង ។ គួរកត់សំគាល់ថា ឡូវែល គឺជាតំបន់នៃសហគមន៍ខ្មែរដ៏ធំបង្អស់ នាផ្នែកខាងកើតនឹងកណ្តាលសហរដ្ឋអាមេរិកដែលគេអាចជ្រើសរើសភោជនីយដ្ឋានខ្មែរដ៏ល្បីៗមានហាងលក់គ្រឿងទេសធំៗហាងកាត់សំពត់អាវគ្រឿងល្អៗគ្រប់បែបរកសិល្បករតំន្ទូរចម្លាក់ស្នូន កែវ ចាន ព្រមទាំងមានទាំងអ្នកឯកទេសខាងច្បាប់ខាងពេទ្យខាងអចលនវត្ថុ ឬសំណង់បានយ៉ាងងាយស្រួល ។ បន្ថែមពីនេះឡូវែលក៏ជាតំបន់នៃសួនឧទ្យានដ៏ត្រកាលដោយសារជាតំបន់ដែលស.រ.អា.ចាត់ទុកថា ជាសួនឧទ្យានប្រវត្តិសាស្ត្រ ។

ដោយសារមានប្រជាពលរដ្ឋដើមកំណើតខ្មែរប្រមាណជា៤ម៉ឺនរស់នៅធ្វើឱ្យឡូវែលបានក្លាយជាក្រុងទី២ នៃចំនួនប្រជាជនខ្មែរច្រើន បន្ទាប់ពីឡុងប៊ិចដែលមានខ្មែរប្រមាណជា៦ម៉ឺននាក់រស់នៅតែចំនួននេះតំណាងឱ្យតែ៣ភាគរយតែប៉ុណ្ណោះនៃប្រជាពលរដ្ឋឡុងប៊ិចទាំងមូល រីឯនៅឡូវែលវិញ ប្រជាពលរដ្ឋខ្មែរតំណាងឱ្យ៣០ភាគរយនៃពលរដ្ឋទាំងមូលដោយសារវិសាលភាពដីតូចជាងឡុងប៊ិច ដូច្នេះធ្វើឱ្យឡូវែលក្លាយជាក្រុងដែលមានខ្មែរជាចំណាត់ថ្នាក់លេខ១ទៅវិញបាន។ ដោយសារចំនួនច្រើននេះហើយ បាននាំឱ្យមានខ្មែរជាប់ឆ្នោតជាក្រុមប្រឹក្សាក្រុងបាន២ដងដែរ...បន្ថែមដោយវត្តមានខ្មែរផុស ស.រ.អាមកឈរជើងនៅឡូវែលតាំងពី៥ឆ្នាំកន្លងមកនេះទៀត ក៏បានជាជំនួយដល់ទំនាក់ទំនងសហគមន៍ចែករំលែកគំនិតថ្មីៗរឹតតែប្រសើរឡើងបាន។ វៀតណាមនឹងឡាវមិនសូវមានវត្តមាននៅឡូវែលច្រើនដូចខ្មែរទេមានភោជនីយដ្ឋាន ខ្លួនខ្លះដែរ រីឯភូមាជាប្រជាជនទើបមកដល់ថ្មីមិនទាន់មានអ្វីទេ។

វត្តអារាមខ្មែរមាន៣ដែលបានបំរើជំនឿខ្មែរខាងព្រះពុទ្ធសាសនាថេរវាទិ គឺ១វត្តត្រៃរតនារាមខាងលើ តទៅទំព័រទី ២៥

MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229
•សេចក្តីអន្តរាយដល់បុគ្គល
•សំណងបុគ្គល
•ពិការភាពដោយសន្តិសុខសង្គម
•បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
•ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
•បណ្តឹងវិវាទទូទៅ
•ច្បាប់ធានារ៉ាប់រង
•ការរំលោភបទព្រហ្មទណ្ឌ
•គ្រោះថ្នាក់ចរាចរណ៍
•គ្រោះថ្នាក់នៅការដ្ឋាន
•បំណុលអចលទ្រព្យ
•បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com

## ពិធីបុណ្យអុំទូកអាស៊ីអាគ្នេយ៍ឆ្នាំ២០១៤

**ដោយ : សុខា**

**ក្រុងឡូវែល:** ឆ្នាំនេះជាឆ្នាំទី១៨ នៃកម្មវិធីដែលនឹងប្រារព្ធបុណ្យអុំទូកអាស៊ីអាគ្នេយ៍នៅក្រុងឡូវែលរដ្ឋម៉ាសាឈូសេតតាមបណ្តោយនៃដងស្ទឹងមែរីម៉ាក់ ឬដែលខ្មែរចំណាំហៅថា ដឹងស្ទឹងឡូវែល។ កម្មវិធីនេះនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៤ ពេញមួយថ្ងៃដោយកម្មវិធីនេះនឹងចាប់ផ្តើមនៅម៉ោងតទៅ។

រៀងរាល់ឆ្នាំមានក្រុមអុំទូកដែលចូលរួមប្រកួត តទៅទំព័រទី ១៤

តមកពីទំព័រ ០៦

## ផ្លាស់ប្តូរអាសយដ្ឋានបោះឆ្នោតនៅឡូវែល...

**ខណ្ឌទី៦, សង្កាត់ទី១**

Ward 6, Precinct 1 ទីតាំងចាស់ Old: McAvinnue School on Mammoth Rd – no change

**ខណ្ឌទី៦, សង្កាត់ទី២**

Ward 6, Precinct 2 ទីតាំងចាស់ Old: Pawtucketville Memorial School ទីតាំងថ្មី New: Bruyere Gardens at D'Youville, 975 Varnum Ave

**ខណ្ឌទី៦, សង្កាត់ទី៣**

Ward 6, Precinct 3 ទីតាំងចាស់ Old: Elks Club on Old Ferry Rd ទីតាំងថ្មី New: Bruyere Gardens at D'Youville, 975 Varnum Ave

**ខណ្ឌទី៧, សង្កាត់ទី១**

Ward 7, Precinct 1 ទីតាំងចាស់ Old: Senior Center on Broadway – no change

**ខណ្ឌទី៧, សង្កាត់ទី២**

Ward 7, Precinct 2 ទីតាំងចាស់ Old: Senior Center on Broadway – no change

**ខណ្ឌទី៧, សង្កាត់ទី៣**

Ward 7, Precinct 3 ទីតាំងចាស់ Old: Senior Center on Broadway – no change

ខណ្ឌទី៨, សង្កាត់ទី១

Ward 8, Precinct 1 ទីតាំងចាស់ Old: Firehouse at Pine & Stevens ទីតាំងថ្មី New: Lowell Health Dept, 341 Pine St

**ខណ្ឌទី៨, សង្កាត់ទី ២**

Ward 8, Precinct 2 ទីតាំងចាស់ Old: Daley School on Fleming St – no change

ខណ្ឌទី៨, សង្កាត់ទី៣

Ward 8, Precinct 3 ទីតាំងចាស់ Old: Daley School on Fleming St – no change ខណ្ឌទី៩, សង្កាត់ទី១

Ward 9, Precinct 1 ទីតាំងចាស់ Old: Polish American Veterans Hall on Coburn St ទីតាំងថ្មី New: Fr Morrissette Manor, Lowell Housing Authority, 111 Hildreth St

**ខណ្ឌទី៩, សង្កាត់ទី ២**

Ward 9, Precinct 2 ទីតាំងចាស់ Old: Robinson School on June St – no change ខណ្ឌទី៩, សង្កាត់ទី ៣

Ward 9, Precinct 3 ទីតាំងចាស់ Old: Robinson School on June St – no change

**ខណ្ឌទី១០, សង្កាត់ទី ១**

Ward 10, Precinct 1 ទីតាំងចាស់ Old: VFW on Plain StNew: Christian Church of Restoration, 53 Blossom St

**ខណ្ឌទី១០, សង្កាត់ទី ២**

Ward 10, Precinct 2 ទីតាំងចាស់ Old: Firehouse on Lawrence St ទីតាំងថ្មី New: Faulkner St Apartments, Lowell Housing Authority

Ward 10, Precinct 3 ទីតាំងចាស់ Old: St Anthony's Parish Hall on Central St – no change

**ខណ្ឌទី១១, សង្កាត់ទី ១**

Ward 11, Precinct 1 ទីតាំងចាស់ Old: Shaughnessy School on Gorham St – no change

**ខណ្ឌទី១១, សង្កាត់ទី ២**

Ward 11, Precinct 2 ទីតាំងចាស់ Old: J.G. Pyne School on Boylston St – no change ខណ្ឌទី១១, សង្កាត់ទី ៣

Ward 11, Precinct 3 ទីតាំងចាស់ Old: J.G. Pyne School on Boylston St – no change

Continued from page 7

## Two Way Traffic in...

Central Street from Market to Merrimack which is now one way heading towards Merrimack will become two way; Merrimack Street from Prescott to Dutton which is now one way heading towards City Hall will be two way;Shattuck Street which runs from Merrimack to Market and is one way heading towards Market will be two way;Market Street from Shattuck to Central which is one way heading towards Central will be two way. Dutton Street will remain two way and Middle and Palmer Street will remain one way as will Prescott Street. There will be new lane markings, cross walks, "no left/right turn" signs, and new parking regulations. It will take a while for everyone to get used to these changes. There are several reasons this is being done: One is to make driving through downtown Lowell easier and more direct; two is to slow traffic and make it easier for people walking; and three is that research shows that stores are more successful with two way traffic.







ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំនាន់បកប្រែសម្រួលពីកាសែតអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ព្រហស្បតិ៍ ទី០៧ ខែសីហា ឆ្នាំ២០១៤

# នួន ជា និង ខៀវ សំផន ត្រូវបានផ្តន្ទាទោសឱ្យជាប់គុកអស់មួយជីវិត

**ដោយ : ល័រិន ក្រុធើរ** | **August 7, 2014**

កាលពីថ្ងៃព្រហស្បតិ៍អតីតមេដឹកនាំខ្មែរក្រហម នួន ជា និង ខៀវ សំផន ជាអតីតប្រមុខរដ្ឋរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានតុលាការខ្មែរក្រហមផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

នួន ជា អាយុ៨៨ឆ្នាំ និង ខៀវ សំផន អាយុ៨៣ឆ្នាំត្រូវតុលាការដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលធ្វើឱ្យប្រជាពលរដ្ឋរស់នៅក្នុងការតក់ស្លុត។

នួន ជា និង ខៀវ សំផន ត្រូវបានរកឃើញថា មានទោសឧក្រិដ្ឋ ចំពោះការទទួលខុសត្រូវក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញកាលពីថ្ងៃទី១៧ខែមេសា ឆ្នាំ១៩៧៥ ការបង្ខំឱ្យប្រជាជនផ្លាស់ទីលំនៅជាពីរដំណាក់កាល និងការសម្លាប់ពួកទាហាន លន់ នុល និងរដ្ឋការនៅកន្លែងដាច់ស្រយាលមួយហៅថា ទួលពោធិ៍ជ្រៃ ក្នុងខេត្តពោធិ៍សាត់ ៕ **វណ្ណ រើន**





Former Khmer Rouge head of state Khieu Samphan, left, and "Brother Number Two" Nuon Chea sit at the Extraordinary Chambers in the Courts of Cambodia as their verdicts were delivered on Thursday morning. (Mark Peters/ECCC)

## Nuon Chea, Khieu Samphan Guilty of Crimes Against Humanity

**By Lauren Crothers | August 7, 2014**

The Khmer Rouge's "Brother Number 2" Nuon Chea and its former head of state Khieu Samphan were on Thursday found guilty of crimes against humanity and sentenced to life in prison by a panel of judges at the Khmer Rouge tribunal.

In front of a courtroom packed with civil parties, regime survivors, government officials and diplomats, Nuon Chea, 88, and Khieu Samphan, 83, were each brought to bear for crimes that Trial Chamber President Nil Nonn said left people living in "a state of terror…unwilling to question orders." They were found guilty of criminal responsibility for the evacuation of Phnom Penh on April 17, 1975, the forced movement of people in two distinct phases and the execution of Lon Nol soldiers and officials at a desolate site in Pursat province called Toul Po Chrey.

Unable to stand to be judged, Nuon Chea was told he had been found "guilty of crimes against humanity encompassing murder, political persecution and other inhumane acts, comprising forced transfer and forced disappearances and attacks against human dignity committed in the territory of Cambodia between April 17, 1975 and December of 1977."

Khieu Samphan, who stood to receive his verdict, was told he too was "guilty of crimes against humanity, of extermination encompassing murder, political persecution and other inhumane acts, conspiring forced transfer, forced disappearances, attacks against human dignity committed in the territory of Cambodia between April 17, 1975 and December 1977."



Soum Rithy, center, who lost his father and three siblings during the Khmer Rouge regime, breaks out in tears and hugs another survivor after the verdict was delivered in the trial of former Khmer Rouge leaders Thursday morning. (Reuters)

# គណបក្សសង្គ្រោះជាតិមានគម្រោងធ្វើជាគណបក្សប្រឆាំងដើម្បីកែប្រែប្រវត្តិសាស្ត្រ

**ដោយ : អេឡិក វិល្លមីនស៍** | **August 7, 2014**

ពីរទសវត្សរ៍បន្ទាប់ពីអង្គការសហប្រជាជាតិបានបង្កើតលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជាតំណាងរាស្ត្រ៥៥រូបរបស់គណបក្សសង្គ្រោះជាតិនឹងចាប់ផ្តើមចូលប្រជុំនៅក្នុងរដ្ឋសភានៅថ្ងៃសុក្រដោយសង្ឃឹមថា នឹងប្រើប្រាស់សមាជិកដ៏ច្រើនរបស់ខ្លួនដើម្បីសម្រេចឱ្យបាននូវអ្វីដែលអ្នកមុនពួកគាត់មិនអាចសម្រេចបាន។

ចាប់ពីការកោះហៅរដ្ឋមន្ត្រីបម្រើការរយៈពេលយូរដែលបានគេចវេះពីការរិះគន់ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៨០ដែលនៅពេលនោះ គណៈកម្មាធិការអចិន្ត្រៃយ៍របស់គណបក្សប្រជាជនកម្ពុជាគឺជាគណៈកម្មាធិការរបស់បក្សកុម្មុយនីស្ត រហូតដល់ការបង្កើត "គណៈរដ្ឋមន្ត្រីស្រមោល" ដែលស្មោះត្រង់លើកដំបូងនៅកម្ពុជានោះ គណបក្សសង្គ្រោះជាតិបាន **តទៅទំព័រទី ១៣**

## CNRP's Plans in Opposition Break With the Past

**By Alex Willemyns | August 7, 2014**

Two decades after the U.N. installed democracy in Cambodia, the CNRP's 55 lawmakers will on Friday begin sitting in the National Assembly with hopes of using their unprecedented numbers in opposition to achieve what others before them could not.

From summoning long-serving ministers who have evaded criticism since the 1980s, when the CPP standing committee was the communist party's politburo, to creating Cambodia's first loyal "shadow cabinet," the CNRP has heralded a new political culture.

resistance leader Son Sann. Sam Sary, the father of CNRP President Sam Rainsy, stands third from the right. (Archives of Sam Rainsy)

"We want the opposition to be recognized as in the British system, as 'Her Majesty's Loyal Opposition,'" CNRP President Sam Rainsy said on July 24. With an alternative government established, a smooth power transfer could take place in 2018, he said.

Yet such plans, which the CPP says would be illegal if implemented (the government imprisoned an opposition official for trying to be a shadow defense minister in 2005) have not gone untested in the country.

Mr. Rainsy, now 65, was in fact 9 when the idea was first tabled, according to prominent French historian Henri Locarde.

"Sam Rainsy's father, Sam Sary, precisely wanted to set up an opposition and even a counter-government on the British model when he had to leave the Cambodian Embassy in London in the '50s," Mr. Locard said. "Sihanouk decided to arrest him. But he had been forewarned by friends in the administration and fled."

Mr. Rainsy's father had formally lodged the request with Prince Sihanouk in January 1959, four years after the prince set up his authoritarian Sangkum Reastr Niyum regime and crushed the Democratic Party that swept elections in 1946, 1947 and 1951.

Mr. Sary instead joined the Khmer Serei rebels, a nationalist and anti-Sihanouk militia based in the north, which former Prime Minister Son Ngoc Thanh had founded with U.S. support. Mr. Sary was shot dead four years later in Laos' border province of Pakse.

Mr. Rainsy wrote in his 2013 memoirs "We Didn't Start the Fire" that his father's inability to create an institutional opposition symbolized a grave deficiency in Cambodia's political culture. **Continued to page 13**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ព្រហស្បតិ៍ ទី០៧ ខែសីហា ឆ្នាំ២០១៤

## តមកពីទំព័រទី ១២ គណបក្សសង្គ្រោះជាតិមានគម្រោងធ្វើ...

បង្ហាញនូវវប្បធម៌នយោបាយថ្មីមួយ។

លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិបានមានប្រសាសន៍កាលពីថ្ងៃទី២៤ ខែកក្កដា ថា "យើងចង់ឱ្យមានការទទួលស្គាល់គណបក្សប្រឆាំងដូចនៅក្នុងប្រព័ន្ធអង់គ្លេស ដូចជាគណបក្សប្រឆាំងដែលស្មោះត្រង់របស់មហាក្សត្រី (Her Majesty'sLoyalOpposition)"។ លោកបានមានប្រសាសន៍ថា បើមានការបង្កើតរដ្ឋាភិបាលមួយផ្សេងទៀត មែនអាចមានការផ្ទេរអំណាចដោយរលូននៅឆ្នាំ២០១៨។

ទោះជាយ៉ាងណាផែនការបែបនេះដែលគណបក្សប្រជាជនកម្ពុជានិយាយថា ជាការខុសច្បាប់ប្រសិនបើមានមែននោះ មិនធ្លាប់មានទេនៅក្នុងប្រទេសនេះ (កាលពីឆ្នាំ២០០៥ រដ្ឋាភិបាលបានចាប់មន្ត្រីគណបក្សប្រឆាំងម្នាក់ដាក់ពន្ធនាគារពីបទព្យាយាមធ្វើជារដ្ឋមន្ត្រីក្រសួងការពារជាតិស្រមោល)។

យោងតាមលោក ហង់រី ឡូកាត ប្រវត្តិវិទូបារាំងដ៏ឆ្នើមបានឱ្យដឹងថា លោក សម រង្ស៊ី ដែលឥឡូវនេះមានអាយុ៦៥ឆ្នាំ តាមពិតលោកមានអាយុតែ៩ឆ្នាំប៉ុណ្ណោះនៅពេលដែលគំនិតនេះត្រូវបានបង្កើតឡើងដំបូង។

លោក ឡូកាត បានឱ្យដឹងថា "លោក សម សារី ឪពុករបស់លោក សម រង្ស៊ី ចង់បង្កើតគណបក្សប្រឆាំងមួយ និងរដ្ឋាភិបាលប្រឆាំងមួយយកគំរូតាមប្រទេសអង់គ្លេសនៅពេលលោកត្រូវចាកចេញពីស្ថានទូតកម្ពុជាប្រចាំទីក្រុងឡុងដ៍កាលពីទសវត្សរ៍៥០។ សីហនុ សម្រេចចាប់ខ្លួនគាត់ ប៉ុន្តែមិត្តភក្តិនៅក្នុងរដ្ឋាភិបាលនោះបានឱ្យដំណឹងដល់គាត់មុន ហើយបានគេចខ្លួន។

ឪពុករបស់លោក សម រង្ស៊ី បានធ្វើសំណើជាផ្លូវការទៅព្រះអង្គម្ចាស់សីហនុ កាលពីខែមករា ឆ្នាំ១៩៥៩ គឺមានរយៈពេលបួនឆ្នាំបន្ទាប់ពីព្រះអង្គបានបង្កើតរបបផ្តាច់ការសង្គមរាស្ត្រនិយម ហើយបានយកជ័យជម្នះលើគណបក្សប្រជាធិបតេយ្យ ដែលបានឈ្នះឆ្នោតនៅឆ្នាំ១៩៤៦-១៩៤៧ និង១៩៥១។

ផ្ទុយទៅវិញ លោក សម សារី បានចូលរួមជាមួយឧទ្ទាមខ្មែរសេរីជាកងជីវពលជាតិនិយមដែលប្រឆាំងនឹង សីហនុ ដែលមានមូលដ្ឋាននៅភាគខាងជើងជាឧទ្ទាមដែលលោក សឺន ង៉ុកថាញ់ អតីតនាយករដ្ឋមន្ត្រីបានបង្កើតឡើងដោយមានការឧបត្ថម្ភពីអាមេរិក។ លោក សម សារី ត្រូវបានបាញ់សម្លាប់បួនឆ្នាំក្រោយមកនៅក្នុងខេត្តប៉ាក់សេរបស់ឡាវ ជាប់ព្រំដែន។

នៅក្នុងកំណត់ប្រវត្តិផ្ទាល់ខ្លួនឆ្នាំ២០១៣របស់លោកដែលមានចំណងជើងថា "យើងមិនបានបង្អាក់ភ្លើង" លោក សម រង្ស៊ី បានសរសេរថា ការខ្វះសមត្ថភាពរបស់ឪពុកលោកក្នុងការបង្កើតគណបក្សប្រឆាំងបានបង្ហាញពីភាពទន់ខ្សោយធ្ងន់ធ្ងរនៅក្នុងវប្បធម៌នយោបាយកម្ពុជា។

លោក សម រង្ស៊ី បានសរសេរថា "ការដែល សម សារី ខ្វះសមត្ថភាពបង្កើតរដ្ឋាភិបាលមួយទៀតសម្រាប់ប្រឆាំងនឹងរដ្ឋាភិបាលនោះបង្ហាញពីភាពទន់ខ្សោយរបស់រដ្ឋសម័យទំនើបដែលលោកបានជួយបង្កើតឡើង។ គំនិតនៃបក្សប្រឆាំងដែលស្មោះត្រង់ និងស្របច្បាប់នេះមិនត្រូវបានទទួលយកទេ"។

លោក ឡូកាត បានបញ្ជាក់ថា "គ្រួសាររបស់លោក សម រង្ស៊ី បានទៅដល់ប្រទេសបារាំងក្នុងឆ្នាំ១៩៦៥ ដោយបានក្លាយជាជនភៀសខ្លួននយោបាយទី១នៅក្នុងទីក្រុងបារីស" ខណៈដែលព្រះអង្គម្ចាស់ សីហនុ លាក់បាំងទង្វើរបស់គណបក្សប្រឆាំងផ្សេងៗក្នុងរយៈពេលប្រាំឆ្នាំ ក្រោយរហូតដល់ព្រះអង្គត្រូវបាន លន់ នល់ ទម្លាក់នៅក្នុងឆ្នាំ១៩៧០។

ជិត៥០ឆ្នាំក្រោយមកការកើនឡើងហួសពីការរំពឹងទុកនៃការគាំទ្រគណបក្សសង្គ្រោះជាតិនៅក្នុងការបោះឆ្នោតកាលពីឆ្នាំ២០១៣អាចធ្វើឱ្យការគាំទ្រលោក ហ៊ុន សែន ដែលបានកាន់អំណាចអស់រយៈពេល២៩ឆ្នាំនោះធ្លាក់ចុះនៅពេលដែលលោកពិចារណាពីការទាមទាររបស់លោក សម រង្ស៊ី និងស្វះស្វែងដាក់សម្ពាធដើម្បីធ្វើឱ្យចុះខ្សោយដល់ការប្រឆាំងដែលកំពុងតែកើនឡើង។

លោក ហ៊ុន សែន គឺជាមនុស្សហេតុការណ៍និយមដ៏ប្រុងប្រយ័ត្នដោយបង្ហាញកម្លាំងចំពោះអ្នកប្រឆាំងទន់ខ្សោយ ប៉ុន្តែបង្ហាញពីការរួចទុក្ខទោសនៅពេលត្រូវបានគំរាមកំហែង។ ផែនការ

តទៅទំព័រទី ២០

Continued from page 12

## CNRP's Plans in Opposition Break ...

"Sam Sary's lack of established alternatives for constructively opposing the state…encapsulates something of the weakness of the modern state that he helped to found," Mr. Rainsy wrote. "The concept of loyal and legitimate opposition was not accepted."

Mr. Rainsy's family arrived in France in 1965, becoming "the first political refugee[s] in Paris," Mr. Locard noted, while the Prince would, over the next five years, juggle various opposition movements with decreasing finesse until he was deposed by Lon Nol in 1970.

Almost 50 years on, the unexpected surge of support for the CNRP at the 2013 election may now offer pause for Mr. Hun Sen, who has been in power for 29 years, as he considers Mr. Rainsy's demands and seeks a pressure valve to diffuse growing dissent.



The first Sangkum Reastr Niyum cabinet of Prince Norodom Sihanouk, center, pose for a photograph in the 1950s. To Prince Sihanouk's left stands Nhiek Tioulong, father of present-day CNRP lawmaker Tioulong Saumura. To the Prince's right stands future prime minister and

Mr. Hun Sen has long been a cautious pragmatist, flexing strength among weak opponents but showing latitude when threatened. And the CNRP's plans could benefit the ruling party if the prime minister sees value in herding dissent into a setting he can manage until other options emerge.

"Still, building a strong opposition in the legislature will not be easy," said John Ciorciari, a Cambodia scholar at the University of Michigan's Gerald R. Ford School of Public Policy. "The CPP has an absolute majority and has historically been effective using honey and vinegar to defuse its opponents in the Assembly."

Mr. Hun Sen has become more authoritarian in his governing style since he was a leading reformist in the late 1980s, but still sits at the apex of a party structure with modern reformists who may come to see the appeal of a loyal opposition, Mr. Ciorciari said.

"Legislative rules and practices that help protect the CNRP today could also be important in any future transfer of power, assuring CPP members that they would enjoy certain institutional protections even if they became a minority party," he said.

Mr. Rainsy said that offering such assurances to the ruling party is more central to the CNRP's efforts to create a loyal opposition in parliament than notions they are on a capacity-building mission.

"We, in the bottom of our hearts, know we won the last election…but we have to be realistic," Mr. Rainsy said. "Our objective now is to create, to try to lay the grounds for a change in the culture."

"The culture is what Hun Sen has spoken about, that 'when the waters flood, the fish eats the ants, and when the waters recede, the ants eat the fish.' We are in this culture of revenge, that any party that comes to power will eliminate the one that was previously in power," he continued.

"The background of our approach now is to create a new culture and to make the people and the CPP less afraid of any regime change, that it will not bring bloodshed and revenge."

Yet people closer to Mr. Hun Sen's trust have in the past failed to create meaningful oppositions in times of even more turmoil.

In the 1980s, as negotiations to end the civil war appeared destined to draw Prince Sihanouk's Funcinpec guerrillas as a political party to contest open elections against the Phnom Penh government, a group of senior communist officials proposed their own new party.

Led by former Council of Ministers chief Ung Phan, who fled the Khmer Rouge regime to Vietnam alongside Mr. Hun Sen in 1977, the group openly proposed a new "Free Social Democratic Party."

Mr. Phan, who was then the communications minister, was "assumed to be protected by his relationship with Hun Sen," noted Evan Gottesman in his book "Cambodia After the Khmer Rouge," which is based on archives and minutes of communist party meetings before Untac.

Nou Saing Khan, a Communications Ministry official who developed the party's manifesto, and Mr. Phan were arrested after they distributed copies of their party manifesto to officials including Mr. Hun Sen and party heavyweight Chea Sim, Mr. Gottesman wrote.

Various officials in the Foreign and Defense ministries, as well as Thun Saray, the current president of rights group Adhoc, who at the time led a communist

Continued to page 21

តមកពីទំព័រទី ១០ ពិធីបុណ្យអុំទូកអាស៊ីអាគ្នេយ៍ឆ្នាំ២០១៤

ដើម្បីដណ្តើមពានរង្វាន់មានបីថ្នាក់ គឺលេខមួយ លេខពីរ និងលេខបីដែលរង្វាន់នីមួយៗមានពានផ្សេងៗពីគ្នា។

ផ្អែកតាមប្រសាសន៍លោក វេន ពេជ្រ ដែលជាប្រធានសមាគមន៍បុណ្យអុំទូកអាស៊ីអាគ្នេយ៍ បានឱ្យដឹងពីសមាសភាពចូលរួមប្រកួតដែលមានចំនួនក្រុម គឺក្រុម ។

ក្រៅពីការប្រកួតភ្ញៀវទស្សនាជិតឆ្ងាយដែលភ្ញូកទឹកភ្លូកដីចូលរួមក្នុងកម្មវិធីបុណ្យអុំទូកអាស៊ីអាគ្នេយ៍នេះនឹងមានឱកាសបានសប្បាយរីករាយទស្សនាការសម្តែង នានាមានរបាំខ្មែរសម្តែងដោយក្រុមរបាំអង្គរនឹងរបាំសាសន៍អាស៊ីអាគ្នេយ៍ដទៃទៀតមាន លាវ ភូមា ថៃជាដើម។ លើសពីនេះទៅទៀត គឺការទទួលទានម្ហូបអាហាររបស់ជនជាតិអាស៊ីអាគ្នេយ៍ដែលមានដាក់លក់ព្រោងព្រាតនៃថ្ងៃនោះ។ មិនតែប៉ុណ្ណោះកម្មវិធីនាថ្ងៃនោះ នឹងមានក្រុមហ៊ុនស្ថាប័ននានាក្នុងសហគមន៍បោះតូបតាំងក្នុងកម្មវិធី ដើម្បីជជែកសំណេះសំណាលរាក់ទាក់ផ្តល់ព័ត៌មានសេវាដែលមានក្នុងស្ថាប័នរបស់ពួកគេ ក៏ដូចជាការចែកជូនវត្ថុអនុស្សាវរីយ៍ជាដើម។

គួរបញ្ជាក់ផងដែរថា ជនជាតិអពៀពមកពីតំបន់អាស៊ីអាគ្នេយ៍ដែលមានប្រពៃណីវប្បធម៌ស្រដៀងគ្នានេះ មានការប្រារព្ធបុណ្យអុំទូកក្រោមអត្ថន័យ និងប្រវត្តិដោយឡែកៗពីគ្នា។


អនុស្សាវរីយ៍អុំទូកឆ្នាំ២០១៣





ពិនិត្យទៅលើប្រវត្តិនៃពិធីបុណ្យអុំទូកខ្មែរ និយាយដោយសង្ខេប គឺការប្រារព្ធនូវការដឹងគុណចំពោះទឹកទន្លេ វារីជាតិដែលបានផ្តល់គ្រប់យ៉ាងផ្គត់ផ្គង់ការរស់នៅរបស់ប្រជាជនខ្មែរបានយ៉ាងល្អប្រសើរ ពោលគឺទឹកជាប្រភពផ្តល់នូវមច្ឆជាតិសម្រាប់ការនេសាទ ទឹកផ្តល់នូវធនធាន និងល្បាប់ក្នុងការដាំដំណាំស្រូវ និងបន្លែបង្ការផ្សេងៗដែលជាគ្រឹះចម្បងនៃកសិកម្មខ្មែរ។ និយាយជារួមដោយសារទឹក មានប្រភពពីទន្លេ បឹង បួរ ស្ទឹងទាំងអស់នេះហើយ ដែលបានផ្តល់គុណបំណាច់ដល់ជីវិតរស់នៅរបស់ខ្មែរដែលមួយភាគធំប្រកបរបរកសិកម្មបានប្រកបការរស់នៅបានស្រួល ទើបប្រជាជនខ្មែរប្រារព្ធបុណ្យអុំទូកនេះឡើង។ បុណ្យអុំទូកនេះ ធ្វើឡើងបីនៅថ្ងៃពេញបូរមីខែកត្តិក តាមឆ្នាំខ្មែរ តាមឆ្នាំបរទេស គឺខែវិច្ឆិកា។

លក្ខណៈពិសេសនៃការប្រារព្ធគឺនៅពេលដែលទឹកហូរបញ្ច្រាត្រឡប់ទៅវិញរវាងបឹងទន្លេសាបនិងទន្លេមេគង្គ។ រីឯការបញ្ចូលនូវការប្រណាំងទូកក្នុងពិធីបុណ្យនេះ គឺដើម្បីរំឭកអំពីអតីតកាលត្រលប់ទៅសម័យព្រះបាទជ័យវរ្ម័នទី៧ នៅពេលដែលទ្រង់ធ្វើសឹកតាមផ្លូវទឹក ហើយទទួលជ័យជំនះ។

រយៈពេលបីថ្ងៃនៃការប្រារព្ធកម្មវិធី នេះមានការប្រារព្ធបីសំខាន់ៗ :

**ទីមួយគឺ ឡយប្រទីបៈ** ដែលធ្វើ

**តទៅទំព័រទី ២៦**



# CMAA of Lowell Has Moved to School Street

# សមាគមខ្មែរផ្លាស់ទីតាំងទៅស្គូលស្ទ្រីតជាស្ថាពរ

**ដោយ : សុខា**

**ក្រុងឡូវែល :** កាលពីថ្ងៃអាទិត្យទី ២៧ ខែ កក្កដា ឆ្នាំ២០១៤ សមាគមខ្មែរបានផ្លាស់អគារធ្វើការពីផ្លូវក្រុសស្ទ្រីតដែលនៅក្បែរម៉ាឃីតបាសឃីត សាខាប្រជរ៉េយ៍ ទៅកាន់ទីតាំងថ្មី គឺស្គូលស្ទ្រីត នៅអាសយដ្ឋាន ៤៥០ School Street ។ តាមប្រសាសន៍លោក សុវណ្ណា ពៅ បានរៀបរាប់ថា យើងផ្លាស់មកកាន់ទីតាំងដែលនៅចំកណ្តាលក្រុងខ្មែរក្នុងភូមិដ្ឋាននៃតំបន់ហៃឡែនដែលមានចម្ងាយមិនឆ្ងាយ គឺអាចដើរបានឆ្លងពីទីកន្លែងមួយទៅកន្លែងមួយទៀត ពោលគឺពីសួនប៉ៃលិន និងហាងនានា ដែលនៅក្នុងតំបន់ក្បែរមជ្ឈមណ្ឌលពាណិជ្ជកម្មប៉ៃលិន។ ទីតាំងថ្មីក៏ផ្តល់លក្ខណៈងាយស្រួលក្នុងការចតយានយន្តផងដែរ ។

សម្រាប់ការផ្លាស់ប្តូរមកទីតាំងថ្មីនេះ ការចាប់ផ្តើមប្រតិបត្តិការការងារ គឺប្រព្រឹត្តទៅនៅជាន់ទីមួយនៃអគារទាំងមូល ។ លោក សុវណ្ណា បន្តថា ទ្វាររបស់សមាគម គឺរង់ចាំបើកទ្វារដល់អ្នករាល់គ្នាដែលរស់នៅក្នុងសហគមន៍ ហើយសមាគមមានជាន់ទីពីរ និងជាន់ក្រោមដីដែលជាទីតាំងដែលសមាគមអាចនឹងយកធ្វើជាទីសម្រាប់ជួលដល់ស្ថាប័ន ឬភ្នាក់ងារដែលធ្វើការសម្រាប់សហគមន៍នាថ្ងៃអនាគត ។

ការផ្លាស់ប្តូរអគារមិនមានការប៉ះពាល់អ្វីដល់ការអនុវត្តកម្មវិធីទាំងឡាយដែលមាននៅក្នុង



Sovanna Pouv Executive Director

សមាគមឡើយ លោក សុវណ្ណា បានមានប្រសាសន៍។ កម្មវិធីទាំង៩នៅក្នុងសមាគមគឺនៅតែមានសកម្មភាពក្នុងនោះមានកម្មវិធីទិញផ្ទះលើកដំបូងសហការណ៍ជាមួយភ្នាក់ងារគេហដ្ឋាននៃមែរីម៉ាក់ដឹកនាំដោយនាយកកម្មវិធី ជីម ដែលដ៍ (Jim Dilde, Director of Merrimack Valley Housing Partnership) ដែលសមាគមបានផ្តល់ភាពជាដៃគូជាមួយ និងមានអ្នកសម្របសម្រួលពីរនាក់នៃសមាគមខ្មែរគឺ សាម៉ាន់តា អ៊ូក (Samantha Ouk) និង ណារ៉េត មឿង (Nareth Muong)

កម្មវិធីសិក្សាភាសាអង់គ្លេសជាភាសាទីពីរ សហការជាមួយមជ្ឈមណ្ឌលសម្រាប់ការអប់រំដល់នីតិជននៅឡូវែល ។

កម្មវិធីមនោរម្យសម្រាប់ជនអសមត្ថភាព ដឹកនាំដោយលោក ប្រាយ អិន ជិន

កម្មវិធីភាសាខ្មែរ ដឹកនាំដោយលោកពុទ្ធារី យ៉ែម

កម្មវិធីអ្នកដឹកនាំវ័យក្មេងដឹកនាំដោយលោក មេត្រី កែវ និង អេវ៉ាន ហន ជាសមាជិកក្នុងគណកម្មការនាយកភ្ជាប់ទំនាក់ទំនងរវាងនិស្សិតមហាវិទ្យាល័យ និងគ្រូដឹកនាំក្នុងសហគមន៍

កម្មវិធីអក្ខរកម្មហិរញ្ញវត្ថុសិក្សាជាមូលដ្ឋានអំពីប្រព័ន្ធធនាគារមានកម្មវិធីផាយឡុតដែលនឹងផ្តល់សកម្មភាពជាច្រើននៅរដូវស្លឹកឈើជ្រុះ

កម្មវិធីសិក្សាអំពីសុខភាពផ្តល់ចំណេះដឹងអំពីជំងឺរលាកថ្លើមប្រភេទ បី ជំងឺគ្រូនិក និងការអប់រំពីការរស់នៅប្រកបដោយសុខុមាលភាព

កម្មវិធីបកប្រែភាសាដែលផ្តល់ការបកប្រែជាលក្ខណៈសេវាកម្មដល់ជំនួញ និងអង្គការមិនគិតប្រាក់ចំណេញ

ការជួយទូទៅដល់ប្រជាជនក្នុងសហគមន៍ដូចជាការបំពេញលិខិតស្នាមសម្រាប់ចូលសញ្ជាតិ អេស អេស អាយ ការទទួលប័ណ្ណផ្សេងៗ និងសេវាជាច្រើនទៀត ។

ត្រឹមពាក់កណ្តាលខែសីហាសមាគមន៍ ទើបផ្លាស់មកទីតាំងថ្មីបានជាងពីរសប្តាហ៍ ហើយមតិក្នុងសហគមន៍ក្នុងពេលដ៏ខ្លីនេះ ចំពោះការផ្លាស់ប្តូរទីតាំង គឺទទួលបាននូវយោបល់វិជ្ជមាន ។ យ៉ាងណាមិញ លោកអ្នកមួយចំនួនបានលើកឡើងថាក្នុងកាលៈទេសៈមានកម្មវិធីណាមួយក្នុងសហគមន៍ទីកន្លែងចតឡានអាចនឹងចង្អៀត ។ តែសមាគមនឹងពិចារណាបន្ថែមទៀតត្រង់ចំណុចនេះ ។ នេះបើផ្អែកតាមប្រសាសន៍របស់លោក សុវណ្ណា ពៅ នាយកប្រតិបត្តិនៃសមាគមខ្មែរ ។

លោក សុវណ្ណា ពៅបានបន្តដូច្នេះថា ខណៈសមាជិកទាំងអស់បានសម្របខ្លួនថ្មីកនឹងកន្លែងថ្មី កាលណាសមាគមនឹងរៀបចំកម្មវិធីទទួលប្រជាជនក្នុងសហគមន៍ឱ្យបានស្គាល់ជាសាធារណៈនូវកន្លែងថ្មី ។

គួរបញ្ជាក់ផងដែរថា សមាគមខ្មែរកំពុងរៀបចំកម្មវិធីដ៏ធំមួយនាពេលខាងមុខ គឺការប្រារព្ធខួប៣០ឆ្នាំ នៃការកកើតសមាគមខ្មែរ កម្មវិធីនេះនឹងប្រព្រឹត្តទៅនៅថ្ងៃសៅរ៍ទី៨ ខែវិច្ឆិកា ឆ្នាំ២០១៤ នាពេលខាងមុខ ៕


## បង្កើតឲ្យមានភាពជោគជ័យ

ធនាគារអ៊ីនធ័រប្រៃ (Enterprise) គឺជាធនាគារដែលទទួលស្គាល់នូវភាពចំរុះគ្នា។
យើងអាចជួយលោក-អ្នកនូវសេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុ គ្រប់យ៉ាងរបស់លោក-អ្នក។



» គណនីសែកផ្ទាល់ខ្លួន, គណនីសន្សំ, ការឲ្យខ្ចីនានា
» និក្ខេប
» ការទាត់ទែងក្នុងការវិនិយោគ
» ធនាគារដែលមិនគិតពីប្រាក់កម្រៃ
» គណនីសែកសំរាប់ជំនួញ, គណនីសន្សំ, ការឲ្យខ្ចីនានា
» គម្រោងសំរាប់ការចូលនិវត្តន៍
» និងជាច្រើនទៀត

យើងនិយាយភាសាខ្មែរ



**Bopha Malone**
*Branch Relationship Manager, AVP*
430 Gorham Street, Lowell, MA
Bopha.Malone@ebtc.com
978-656-5561



**Sue Suon**
*Branch Service Specialist*
222 Merrimack Street, Lowell, MA
Sue.Suon@ebtc.com
978-656-5679

សូមនិយាយជាមួយបុប្ផា ម៉ាឡូន ឬស៊ូ សួន ថ្ងៃនេះ
ហើយឲ្យគេជួយលោក-អ្នកបង្កើតឲ្យមានភាពជោគជ័យ!

Enterprise Bank
CREATE SUCCESS

EnterpriseBanking.com

FDIC

# មានមេធាវីខ្មែរថ្មីនៅឡូវែល

**ដោយខ្មែរផុស ស.រ.អា.**

លោក ម៉ាជូ តាំង ទើបនឹងបើកទីតាំងទីបំរើការណ៍ផ្នែកច្បាប់ក្នុងក្រុងដែលមានខ្មែរច្រើនរស់នៅនាទីក្រុងឡូវែល

លោកជាមេធាវីខ្មែរនិយាយភាសាខ្មែរជ្រៅជ្រះទីពាដែលមានអាជ្ញាប័ណ្ណកំពុងបំរើសហគមន៍មួយដែលសម្បូរអ្នកត្រូវការអ្នកឯកទេសការពារប្រជាពលរដ្ឋនៅចំពោះមុខច្បាប់អាមេរិកាំង ។ លោកនិយាយថា លោកបានរៀនចប់មហាវិទ្យាល័យច្បាប់ស្រុកខ្មែរតាំងពីមកដល់នាឆ្នាំ២០០៥ លោកនៅបំរើជាជំនួយការ៨ឆ្នាំ នៅការិយាល័យច្បាប់លោក ឡូវីស ហេស្កល់ នៅទីនោះលោកធ្វើការផងរៀនផង រហូតដល់បានបញ្ចប់សញ្ញាប័ត្រច្បាប់សហរដ្ឋអាមេរិកនឹងប្រឡងយកអាជ្ញាប័ណ្ណពីសមាគមមេធាវីបាន កាលពីចុងឆ្នាំមុននេះ ទៀតផង។ សព្វថ្ងៃលោកកាន់ករណីរដ្ឋបវេណីចំនួន ១០០ដែលធ្វើពីដោះស្រាយទំនាស់ដីធ្លីគ្រោះថ្នាក់ចរាចរ ការបណ្តេញចេញពីស្រុក...។ល។ តែមិនធ្វើករណីឧក្រិដ្ឋទេ ។

លោក ម៉ាជូ តាំង បាននិយាយថា គឺជាការងារដែលលោកចូលចិត្តជួយដោះស្រាយបញ្ហាផ្លូវច្បាប់ដោយនិយាយជាភាសាខ្មែរជាមួយនឹងខ្មែរ បើទោះជាមានប្រើសេវាអ្នកបកប្រែក៏ដោយក៏មិនដូចចិត្តអ្នកនិយាយភាសាខ្មែរដូចគ្នាដែរ



Andrew Taing, Attorney at Law

លោកបន្តរថា បើខ្មែរយើងមកពីគ្រោះយោបល់ពិជំណោះស្រាយផ្លូវច្បាប់លោករីករាយនឹងជួយដោយមិនយកកំរៃទេ។

ខ្មែរដែលមានឯកទេសជាអ្នកការពារច្បាប់មិនសូវមានទេ សម្បូរតែអ្នករត់ការណ៍ដោយ




1550 Middlesex Street Lowell, MA 01851

សារតែការអប់រំពីកុមារភាពគឺ គេចចេញពីបណ្តាញច្បាប់ឬក្បួនតម្រាមិនប្រឈមមុខទេ ដូចជាប្រដៅកូនចៅថា កុំឈ្លោះនឹងស្រីកុំក្តីនឹងចិនជាដើម ។ វិជ្ជាជីវៈរបស់ លោក ម៉ាជូ តាំងនឹងភាពសម្បូរនិស្សិតសាលាច្បាប់នៅស្រុកខ្មែរបច្ចុប្បន្ននិស្សិតស្រីក៏សម្បូរណាស់ដែរ គឺជាសញ្ញាច្បាស់លាស់មួយនៃការប្តូរចរន្តគំនិតពីខ្មែរស៊ុតទ្រុឌមិនចោលចែចូវនោះហើយ ៕


# ហ្វេយ៍មីកខេប ផ្ទះសម្រាប់ពិធីបុណ្យសព

# Fay Mccabe Funeral Home

105 Moore Street. Lowell, MA 01852

**978-459-9222**

**បម្រើសហគមន៍ខ្មែរដោយការយកចិត្តទុកដាក់ កិត្តិយស និងការគោរពជាង៣០ឆ្នាំមកហើយ**

- Serving All Faiths បម្រើសម្រាប់ការប្រកាន់គ្រប់ជំនឿ
- Traditional Funerals កម្មវិធីបុណ្យសពជាលក្ខណៈប្រពៃណី
- Cremation Services មានផ្តល់សេវាបីជាសព
- Pre Arranged Funerals គ្រោងជាមុនរៀបចំកម្មវិធីបុណ្យសព



Locates 1 mile from Glory Buddhist Temple, between Gorham St. & Lawrence St.

ទីកន្លែងនៅចំងាយ១ម៉ាយពីវត្តពន្លឺពុទ្ធិចក្រ ចន្លោះហ្គហាំ និងឡរ៉ែន

***លោកអ្នកនឹងក្រុមគ្រួសារទទួលបាននូវការយកចិត្តទុកដាក់ និងការបម្រើល្អប្រពៃពីទីនេះ ។***

www.faymccabe.com

**មានបុគ្គលិកនិយាយភាសាខ្មែរ**

AccuCare Home Care Agency
Group Adults Foster Care Program

# Homecare Agency

Group Adult Foster Care Program (GAFC)
MassHealth

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្ដានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



*Compassionate Care & Reliable*
*Professional & Cultural Sensitive*
*Management & Staffs speak Khmer*

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្ដល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្ដង ។

*Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.*

## ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

To be eligibled for GAFC you must:

-រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)
-អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)
-មាសហែលស្ទេនដា (eligible for Masshealth Standard)
-ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀក-ពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)
-មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអក (have physician statement of your condition)
-ត្រូវបានវាយតំលៃផ្នែកសុខភាព និងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )

## ផលប្រយោជន៍ទទួលបាន :

Benefits you will get:

-ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)
-ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)
-ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ (an individual care plan developed by a registered nurse and case manager)
-វាយតំលៃលើសេចក្ដីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)
-សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:

ឱក តុលាយុត្តិ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852



**PERFROMANCE SCHEDULE**

A. SEPTEMBER 20, 2014 SOMPAO MEAS HALL 450 CHELMSFORD MASS. 01851
B. SEMPTEMBER 27, 2014
C. OCTOBER 4, 2014 FIVE STAR REST. 43 BUCKING ST. PROVIDENT RI
D. OCTOBER 11.14 New Fortune Rest. 16515 S. Frederick Gaithersburg md
E. OCTOBER 18. 2014
S. CORILINA
F. OCTOBER 25. 2014 St. Michael Lynn mass
g. Nov. 1, 2014 Hong kong Royal Carrolton tx.
h. nov 8. 2014 Atlanta Gorgia
i. nov. 15. 2014 White eagle hall Chicago
J. nov. 22 2014 Dragon court
n. Carolina
K. Nov 29, 2014 Seatle Washington
L. dec. 6 Stocton cal.
m. dec. 20 Portland Oregon
n. Dec. 27 Austin texas
o. Jan 10. 2015 Sompoa meas hall lowell mass. 01851

**OFFICE;**
296 WESTFORD STREET.
LOWELL MASS. 01851
CONTACT INFORMATION
SENGHAP ROUEUN
**978 888 8099,**

ASALEC

# AMERICAN

# SOUTHEAST ASIAN LITERARCY AND EDUCATIONAL COUNSELING

# កម្មវិធីវប្បធម៌ខ្មែរ

សូមចូលរួមជាមួយយើងខ្ញុំ ក្នុងការអបអរសាទរការតម្លើងវប្បធម៌ និងប្រវត្តិសាស្ត្រខ្មែរ ជាមួយអ្នកសិល្បៈចម្រៀង និងសម្ដែង

**Activities:**

1. Video presentation (Khmer tradition dance)
2. Live Band Performance (Traditional Music mix with modern music)
3. Sing along (karaoke )
4. Social/education (Senior adult day care participation. After school children performance




បេសកកម្ម : ដើម្បីរក្សា និងបន្តអាទិភាពវប្បធម៌ និងប្រវត្តិសាស្ត្រខ្មែរ

# សេដ្ឋកិច្ចគ្រួសារខ្មែរ និងវិបត្តិសង្គមខ្មែរ




*និពន្ធដោយ : ដេវីដ សេង. អនុបណ្ឌិតវិទ្យាសាស្ត្រគ្រប់គ្រងសង្គមកិច្ច*

សង្គ្រាមរ៉ាំរ៉ៃកើតក្នុងប្រទេសខ្មែរ និងការឈ្លានពានពីប្រទេសជិតខាងបានទាញសេដ្ឋកិច្ចគ្រួសារខ្មែរឱ្យធ្លាក់ចូលរណ្តៅមរណៈជីវភាពក្រខ្សត់តៗគ្នាគ្រប់ជំនាន់ ។ ភាពក្រខ្សត់នេះហើយដែលបានបង្ខំចិត្តខ្មែរខ្លះឱ្យធ្វើរឿងខុសសីលធម៌ ដើម្បីដោះស្រាយក្រពះ និងជីវភាពគ្រួសារ ។ អ្នកខ្លះហ៊ានលក់កូនស្រីដើម្បីជីវភាពគ្រួសារទោះ ជាដឹងថា វាជាអំពើខុសច្បាប់មិនមែនជាមធ្យោបាយដ៏ល្អប្រសើរក៏ដោយ ។ ប្រសិនបើរឿងប្រៀងធៀបនឹងប្រទេសដ៏ទៃ សេដ្ឋកិច្ចខ្មែរគឺដើរថយក្រោយយ៉ាងតិច៤០ឆ្នាំក្រោយប្រទេសជិតខាងដូចជាប្រទេសថៃ.កូរ៉េខាងត្បូង.ហុងកុង និងតៃវ៉ាន់ ។

បន្ទាប់ពីសង្គ្រាម.ខ្មែរដែលសល់ពីស្លាប់ក្នុងរបបខ្មែរក្រហមតែងតែពោលពាក្យថា : គាត់មិនចង់បានអ្វីក្រៅអំពីចង់ឱ្យតែមានបាយហូបពីរពេលក្នុងមួយថ្ងៃ គឺគាត់គ្រប់គ្រាន់ហើយ ។ នេះគឺជាសម្តីអស់សង្ឃឹមនៃជីវិតរបស់គាត់គ្មានផ្លូវដើរ និងការបាត់បង់ជំនឿចិត្តថាខ្លួនគាត់អាចមានភាពប្រសើរឡើងវិញ ។ ខ្មែរភាគច្រើនបានបាត់បង់ក្តីសង្ឃឹមថាខ្លួន គាត់ជាម្ចាស់ការនៃជីវិតខ្លួន ។ ខ្មែរដែលរស់នៅជំរុំជនភៀសខ្លួនតាមព្រំដែនខ្មែរ-ថៃមានវាសនាបានមករស់នៅសហរដ្ឋអាមេរិកខិតខំប្រកបការងារ ដើម្បីចិញ្ចឹមជីវិត និងប្រកបការងារធ្ងន់ៗដែលជនជាតិដ៏ទៃមិនចង់ធ្វើ ប៉ុន្តែពួកគាត់មិនខ្លាចនឿងហត់ឡើយ ដើម្បីចិញ្ចឹមជីវិតគ្រួសារ ។

ក្នុងសម័យអង្គរខ្មែរជាពូជពូកែក្នុងទ្វីបអាស៊ីអាគ្នេយ៍ហើយខ្មែរនេះឯងបានធ្លាប់គ្រប់គ្រងជាតិដ៏ទៃកាលជំនាន់មហាចក្រខ្មែរ ។ ប្រទេសជិតខាងតែងតែខ្លាចខ្មែរងើបឡើង និងរើបម្រះខ្លួនរួចពីសភាពក្រខ្សត់ដូចសព្វថ្ងៃនេះ ។ ខ្មែរសព្វថ្ងៃកំពុងជួប និងវិបត្តិសេដ្ឋកិច្ចប្រចាំគ្រួសារវិបត្តិផ្លូវចិត្តដែលមិនទាន់ព្យាបាល និងវិបត្តិសង្គម-នានា ដែលយើងត្រូវតែរកកម្មវិធីមកដោះស្រាយជាបន្ទាន់ដើម្បីការរស់នៅ និងភាពរុងរឿងរបស់ខ្មែរទៅអនាគត ។

កាលសម័យខ្មែរក្រហមគ្មានអ្នកក្រ-គ្មានអ្នកមាន.គ្មានទីផ្សារ.គ្មានតុលាការកាត់ក្តី.គ្មានសិទ្ធិ.គ្មានធនាគារជាតិ.គ្មានវិនិយោគទុនអ្វីទាំងអស់ ។ ជីវិតមនុស្សទាំងអស់គឺដាក់ឱ្យអង្គការជាអ្នកសម្រេចជីវិត និងជោគវាសនា ។ ខ្មែរបានស្លាប់បាត់បង់ជីវិតប្រហែលជាង៣លាននាក់ក្រោមការដឹកនាំដ៏មហាអស្ចារ្យមហាលោតផ្លោះរបស់ខ្មែរក្រហម ។ តើអ្នកមានដែលបានពិចារណាថាហេតុអ្វីបានជាគេសម្លាប់អ្នកចេះដឹងនិស្សិតបញ្ញវ័ន្តខ្មែរអស់ហើយគេថែមទាំងបានជំរិតយកលុយកាក់មាសពេជ្ររបស់ប្រជាជនទុកជាទ្រព្យសម្បត្តិហាភាព ឬសម្បត្តិរបស់អង្គការ ។ នេះហើយជាក្បួនបំបាក់ស្មារតីទាំងកម្លាំងកាយ និងកម្លាំងចិត្តខ្មែរម្នាក់ៗមិនឱ្យអ្នកមានគំនិតស៊ូប្រឆាំងនូវគម្រោងការដែលពួកគេកំពុងអនុវត្តន៍ ។ ទ្រព្យសម្បត្តិទាំងអស់នោះ បានដឹកជញ្ជូនទៅប្រទេសដ៏ទៃ និងមេបញ្ជាការរបស់ជនជាតិដ៏ទៃបានកប់ទុកយកទ្រព្យសម្បត្តិខ្មែរអស់នោះ បន្ទាប់ពីសង្គ្រាមមកក្លាយជាមហាសេដ្ឋីក្នុងស្រុកខ្មែរសព្វថ្ងៃនេះ ។

ខ្មែរយើងបានមករស់នៅសហរដ្ឋអាមេរិកជាង៣៥ឆ្នាំកន្លងមកហើយ. ខ្មែរយើងត្រូវតែរៀនដឹងអំពីជនជាតិដ៏ទៃថា គេធ្វើអ្វីខ្លះ ដើម្បីភាពប្រសើរនូវសេដ្ឋកិច្ចគ្រួសារ ។ យើងទាំងអស់គ្នាដឹងហើយថា យើងមិនអាចពឹងថ្នាក់ដឹកនាំខ្មែរ ឬអ្នកនយោបាយណាមួយមកជួយគ្រួសារអ្នកឱ្យបានធូរស្បើយ ឬមានសេដ្ឋកិច្ចប្រសើរក្នុងគ្រួសារអ្នកឡើយ ។ អ្នកត្រូវតែខំខ្លួនឯង.អ្នកនយោបាយទាំងអស់នោះមិនអាចជួយអ្នកឡើយ ។

ប្រជាជនខ្មែរជាមនុស្សមានគំនិតណាស់ជាពិសេសការសន្សំលុយកាក់ទុក ប៉ុន្តែក្បួនទាំងអស់នោះជាក្បួនចាស់ដែលអាចធ្វើឱ្យអ្នកខាតបង់គ្មាននរណាទទួលខុសត្រូវឡើយ ខ្មែរយើងបានយកក្បួនបូរាណមកប្រើប្រាស់ក្នុងការសន្សំលុយដូចជា : យកលុយសុទ្ធទៅលាក់ទុកក្នុង ឬក្រៅផ្ទះ (ចោរអាចលួច ឬប្លន់អ្នកបាន).សន្សំលុយទុកក្នុងធនាគារដែលមានការប្រាក់ទាបបំផុត (ធនាគារយកលុយអ្នកទៅឱ្យគេខ្ចីយកការប្រាក់ខ្ពស់សម្រាប់ចំណេញ ហើយប្រសិនបើអ្នកខ្ចីលុយពីធនាគារវិញ គឺគេយកការប្រាក់អ្នកខ្ពស់) ការសន្សំលុយរបៀបលេងតុងទីន(មេបោកប្រាស់ ឬមានកូនដេញ ហើយរត់ចោលមិនសងលុយ. ខ្មែរភាគច្រើនមានបទពិសោធន៍រឿងនេះជាច្រើន ប៉ុន្តែដោយសារគាត់គ្មានវិធីផ្សេង ឬក្បួនសន្សំលុយផ្សេង. គាត់ក៏បានជ្រើសរើសផ្លូវនេះ ដើម្បីធ្វើការសន្សំលុយកាក់គាត់) ។ **តទៅទំព័រទី ១៩**


រោងជាង រចនា

LEGEND
AUTO BODY INC.

អាស័យដ្ឋាន 115 Rock St. #7 Lowell, MA 01854
សូមទំនាក់ទំនង **អាដាំ អ៊ា** : 978-458-2085

ជួសជុលយានយន្តលោកអ្នកប្រកបដោយគុណភាព

Lowell Finest Quality of Body Work

**មានបម្រើ**
- ជួសម៉ាស៊ីនយានយន្ត
- ប្រភេទយានយន្តក្នុង និងក្រៅប្រទេស

**តួយានយន្ត**
- បញ្ជាក់ប័ណ្ណធានារ៉ាប់រងទទួលស្គាល់ដោយរដ្ឋ

**ដឹកឡានត្រូវចត** 978-815-9957 (ខេ-ស៊ី)



115 Rock St. Unt #7 Lowell, MA 01854

រោង ជាង រចនា



LEGEND
AUTO BODY INC.
(978) 458-2085

**Services**
- Auto Body
- Auto Mechanics
- Foreign and Domestics
- State and Insurance Certified

Towing - **978-815-9957** (K.C)



## តមកពីទំព័រទី ១៨ សេដ្ឋកិច្ចគ្រួសារខ្មែរ និងវិបត្តិសង្គម...

ដូចខ្ញុំបានរ៉ាយរ៉ាប់ខាងលើរួចមកហើយខ្មែរយើងមិនមែនជាមនុស្សចោលម្សៀតទេ តាមការពិតគាត់ឆ្លាតណាស់ ហើយតែងតែគិតពីអនាគតរបស់គ្រួសារ និងជាតិជានិច្ច ។ ក្នុងសង្គមខ្មែរគ្រប់រដ្ឋខ្ញុំតែងឃើញសកម្មភាពសមាគមមរណៈសង្គ្រោះវត្តនីមួយៗដើម្បីជួយយាយៗតាៗដែលគាត់ខ្វះខាតលុយកាក់នៅពេលដែលគាត់ទទួលមរណៈភាពទៅ ដើម្បីឱ្យកូនចៅបានធូរខ្លះក្នុងការរៀបចំទុកដាក់សពគាត់ ។ នេះជារឿងល្អដែលសង្គមសាសនាបានបង្កើតជួយក្នុងសង្គមខ្មែរ ពីព្រោះគាត់មិនបានដឹងអំពីអិនស្សូរិនការពារជីវិត និងក្បួនសន្សំលុយកាក់ដែលមានអិនស្សូរិនការពារជីវិតជាមួយគ្នាដែលអាចជួយដល់គ្រួសារអ្នកឱ្យមានសេដ្ឋកិច្ចប្រសើររបៀបណា ។ ទោះជាយ៉ាងណាក៏ដោយក៏យើងអាចវិនិច្ឆ័យថា ខ្មែរជាជនជាតិមានគំនិតទុកដាក់សម្រាប់អនាគតពួកគាត់ ។ ខ្មែរសឹងគ្រប់រូបមានឡានជិះមានផ្ទះរស់នៅមានការងារធ្វើទោះជាការងារលំបាកយ៉ាងណាក៏ខ្មែរតស៊ូដែរ ។ ខ្មែរមួយចំនួនតូចបំផុតដែលគាត់គ្មានផ្ទះសម្បែងរស់នៅដោយសារគាត់មានវិបត្តិផ្លូវចិត្ត ឬញៀនគ្រឿងស្រវឹងអ្វីមួយ ។ ជនជាតិខ្មែរមានប្រវត្តិស្រដៀងជនជាតិជ្វីហ្វ(អ៊ីស្រាអែល)ដែលបានឆ្លងកាត់សោកនាដកម្មដូចជនជាតិខ្មែរក្នុងសង្គ្រាមលោកលើកទី២ នៅពេលដែលជនជាតិអាល្លឺម៉ង់សម្លាប់ជនជាតិជ្វីស(អ៊ីស្រាអែល)រាប់លាននាក់ដើម្បីបំបាត់ពូជសាសន៍នេះឱ្យបាត់ពីពិភពលោកដូចដែលគេចង់បំបាត់ពូជខ្មែរដែរ ពីព្រោះការ



ប្រកាន់ពូជសាសន៍ ។ សព្វថ្ងៃនេះជនជាតិខ្មែរជ្វីស គឺជាមហាសេដ្ឋី និងអ្នកមានអំណាចជាងគេក្នុងសហរដ្ឋអាមេរិក ។ សង្គ្រាមរវាងជនជាតិផាលិស្ទិនីន និងអ៊ីស្រាអែល. អាមេរិកតែងតែកាន់ជើងប្រទេសអ៊ីស្រាអែលថែមទាំងជំនួយលុយកាក់ក្នុង១ឆ្នាំជាង៣កោដិដុល្លារថែមទៀតព្រមទាំងអាវុធទំនើបៗ ។ ហេតុអ្វីបានជាជនជាតិមួយដែលមានប្រវត្តិស្រដៀងខ្មែរយើងក្លាយទៅជាអ្នកមានអំណាច និងមហាសេដ្ឋីក្នុងពិភពលោក? រឿងទាំងអស់នេះមិនមែនកើតឡើងដោយចៃដន្យនោះទេ ។ អ្វីៗត្រូវមានគម្រោងក្នុងជីវិត និងមាគាដើរឆ្ពោះទៅគោលដៅដែលអ្នកចង់បាន ។ ជនជាតិជ្វីសភាគច្រើនពូកែសន្សំលុយ និងទិញអិនស្សូរិនការពារជីវិត និងការពារហេតុការណ៍ធំៗក្នុងជីវិត ជាពិសេសពេលគេមានជំងឺ.ចាស់ជរា. មរណៈ, និងការសន្សំលុយ ។ ប្រជាជនជ្វីសរស់នៅសហរដ្ឋអាមេរិកមានចំនួនតែ២ភាគរយនៃប្រជាជនអាមេរិកាំងចំនួន៣១៧លាននាក់.២៥ភាគរយនៃមហាសេដ្ឋី៤០០នាក់នៅសហរដ្ឋអាមេរិក គឺជនជាតិជ្វីស ។ លោក ហ្វប ជាមហាសេដ្ឋីជនជាតិជ្វីសមានប្រាក់២.៧កោដិ ។ ជនជាតិជ្វីសមានទាំងអ្នកនយោបាយក្នុងសភា២៧នាក់ក្នុងសភាចំនួន៤៣៥នាក់ប្រចាំសហរដ្ឋអាមេរិក. ជនជាតិជ្វីសមានវេជ្ជបណ្ឌិត៨០.០០០ទៅ១០០.០០០នាក់ ។ តើខ្មែរអាចក្លាយទៅជាប្រជាជនដែលមានលុយ និងអំណាចទេ ? តើខ្មែរអាចរកឃើញនូវវិធី ឬរូបមន្តកសាងជាតិខ្លួនឱ្យក្លាយជាជាជនគំរូដូចសម័យអង្គរបានទេ? មានតែពេលវេលាទេដែលអាចដឹងការពិត ប៉ុន្តែអ្នកមិនអាចដេកចាំព្រេងសំណាងឡើយ. អ្នកត្រូវតែខំខ្លួនឯងហើយត្រូវមានគម្រោងដើរឆ្ពោះទៅមុខ ។

យើងដឹងហើយថា ក្នុងលោកនេះគ្មានអ្វី ឬនរណាម្នាក់អាចប្រឆាំងនឹងច្បាប់ធម្មជាតិបានទេ សូម្បីតែព្រះពុទ្ធ ឬព្រះយេស៊ូគ្រីស និងព្រះអាឡាក៏លោកគេចមិនផុតពីភាពចាស់.ជរា.ឈឺ.និងមរណៈភាពដែរ ។ មនុស្សកើតមកហើយតែងតែឈឺចាស់ និងមរណៈភាពជាធម្មតាទេ គ្មានបុគ្គលណាអាចគេចផុតពីសេចក្តីស្លាប់បានទេ ។ ប្រសិនបើអ្នកដឹងថា នេះជារឿងពិតហើយ តើអ្នកចង់រស់នៅដោយគ្មានគម្រោងឬទេ? តើអ្នកត្រូវដាក់

តទៅទំព័រទី ២៣






តមកពីទំព័រ ១៣

## គណបក្សសង្គ្រោះជាតិមានគម្រោងធ្វើ...

របស់គណបក្សសង្គ្រោះជាតិអាចផ្តល់ផលប្រយោជន៍ដល់គណបក្សកាន់អំណាច ប្រសិនបើលោកនាយករដ្ឋមន្ត្រីមើលឃើញប្រយោជន៍នៅក្នុងការប្រមូលអ្នកប្រឆាំងឱ្យចូលទៅក្នុងក្រុមតែមួយតាមដែលលោកអាចគ្រប់គ្រងបាន រហូតដល់មានជម្រើសផ្សេងទៀត។

លោក JohnCiorciari សាស្ត្រាចារ្យបង្រៀនអំពីកម្ពុជានៅមហាវិទ្យាល័យគោលនយោបាយសាធារណៈ GeraldR. Ford នៃសាកលវិទ្យាល័យមីឈីហ្គែនបាននិយាយថា "ទោះជាយ៉ាងណាការបង្កើតគណបក្សប្រឆាំងខ្លាំងមួយនៅក្នុងរដ្ឋសភាមិនមែនជាការងាយស្រួលទេ។ គណបក្សប្រជាជនកម្ពុជាមានសំឡេងភាគច្រើនដាច់ខាត និងមានប្រវត្តិប្រើប្រាស់វិធានការល្អ និងអាក្រក់យ៉ាងមានប្រសិទ្ធភាពជាយូរមកហើយ ដើម្បីធ្វើឱ្យអ្នកប្រឆាំងរបស់ខ្លួននៅក្នុងរដ្ឋសភាចុះខ្សោយ"។

លោក Ciorciari បាននិយាយថា លោក ហ៊ុន សែន មានអំណាចផ្តាច់ការកាន់តែខ្លាំងនៅក្នុងការដឹកនាំរបស់លោកចាប់ តាំងពីលោកបានក្លាយជាអ្នកកែទម្រង់និយមនាំមុខគេនៅចុងទសវត្សរ៍ឆ្នាំ១៩៨០ ប៉ុន្តែនៅតែមានអំណាចកំពូលនៅក្នុងរចនាសម្ព័ន្ធគណបក្សដែលមានអ្នកកែទម្រង់និយមសម័យទំនើបដែលចង់ឃើញសំណើរបស់គណបក្សប្រឆាំងស្មោះត្រង់។

លោកបាននិយាយថា "ច្បាប់ និងការអនុវត្តនានាដែលអាចជួយការពារគណបក្សសង្គ្រោះជាតិសព្វថ្ងៃនេះក៏មានសារៈសំខាន់ផងដែរ នៅក្នុងការផ្ទេរអំណាចនាពេលអនាគតដោយធានាអះអាងចំពោះសមាជិកគណបក្សប្រជាជនកម្ពុជាថាពួកគេនឹងទទួលបានការការពារពីស្ថាប័នណាមួយប្រសិនបើពួកគេបានក្លាយជាគណបក្សដែលមានសំឡេងតិច"។

លោក សម រង្ស៊ី បានមានប្រសាសន៍ថា ការអះអាងបែបនេះចំពោះគណបក្សកាន់អំណាចមានសារៈសំខាន់សម្រាប់ការខិតខំប្រឹងប្រែងរបស់គណបក្សសង្គ្រោះជាតិក្នុងការបង្កើតគណបក្សប្រឆាំងដែលស្មោះត្រង់នៅក្នុងរដ្ឋសភា។

លោក សម រង្ស៊ី បានមានប្រសាសន៍ថា "យើងដឹងយ៉ាងច្បាស់ថា យើងឈ្នះការបោះឆ្នោតចុងក្រោយនេះ ប៉ុន្តែយើងត្រូវតែប្រាកដ។ គោលបំណងរបស់យើងឥឡូវនេះ គឺដើម្បីបង្កើតព្យាយាមធ្វើឱ្យមានការផ្លាស់ប្តូរនៅក្នុងវប្បធម៌នេះ"។

លោកបានបន្តទៀតថា "វប្បធម៌នេះគឺជាវប្បធម៌ដែល ហ៊ុន សែន បាននិយាយ "នៅពេលទឹកឡើងត្រីស៊ីស្រមោចនៅពេលទឹកហោចស្រមោចស៊ីត្រី។ យើងកំពុងស្ថិតនៅក្នុងវប្បធម៌សងសឹកនេះ គឺថាគណបក្សណាដែលឡើងកាន់អំណាចនឹងលុបបំបាត់អ្នកកាន់អំណាចមុន"។

"ដំណោះស្រាយរបស់យើងនៅពេលនេះ គឺដើម្បីបង្កើតវប្បធម៌ថ្មីមួយ និងធ្វើឱ្យប្រជាជន និងគណបក្សប្រជាជនកម្ពុជាមិនមានការភ័យខ្លាចអំពីការផ្លាស់ប្តូររបបដែលនឹងមិននាំឱ្យមានការបង្ហូរឈាម និងការសងសឹក"។

ទោះជាយ៉ាងណាមនុស្សដែលជិតធ្វើឱ្យលោក ហ៊ុន សែន ទុកចិត្តមិនបានបង្កើតគណបក្សប្រឆាំងដ៏មានន័យទេ នៅពេលណាមានភាពចលាចលកាន់តែខ្លាំងនោះ។

កាលពីទសវត្សរ៍ឆ្នាំ១៩៨០នៅពេលដែលការចរចាបញ្ចប់សង្គ្រាមស៊ីវិលហាក់ដូចជាដើម្បីទាក់ទាញឧទ្ទាមហ៊្វុនស៊ិនប៉ិចរបស់ព្រះអង្គម្ចាស់សីហនុឱ្យធ្វើជាគណបក្សនយោបាយសម្រាប់ប្រកួតប្រជែងនៅក្នុងការបោះឆ្នោតទូទៅប្រឆាំងនឹងរដ្ឋាភិបាលក្រុងភ្នំពេញនោះ មន្ត្រីកុម្មុយនីស្តមួយក្រុមបានស្នើបង្កើតគណបក្សថ្មីរបស់ខ្លួន។

ដឹកនាំដោយលោក អ៊ុង ផាន អតីតប្រធានទីស្តីការគណៈរដ្ឋមន្ត្រីដែលបានភៀសខ្លួនពីរបបខ្មែរក្រហមទៅប្រទេសវៀតណាមនៅក្នុងឆ្នាំ១៩៧៧ ក្រុមនេះបានស្នើដោយចំហបង្កើតគណបក្សប្រជាធិបតេយ្យសង្គមសេរី។

លោក អ៊ីវ៉ាន ហ្គុតថេសមែនបានបញ្ជាក់នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើង "កម្ពុជាក្រោយរបបខ្មែរក្រហម" ដែលផ្អែកតាមឯកសារបណ្ណាល័យ និងកំណត់ហេតុនៃកិច្ចប្រជុំរបស់បក្សកុម្មុយនីស្តមុនសម័យអ៊ុនតាក់ថា កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩០ សំណើរបស់លោក ផាន សុំបង្កើតគណបក្សនេះត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រី។

លោក ហ្គុតថេសមែន បានសរសេរថា លោក ផាន និងលោក នូ សាំងខន មន្ត្រីក្រសួងទូរគមនាគមន៍ដែលបានបង្កើតគោលនយោបាយបក្សនេះ ក្រោយមកត្រូវបានចាប់ខ្លួននៅខែមេសាបន្ទាប់ពីពួកគាត់បានចែកចាយគោលនយោបាយរបស់បក្សពួកគាត់ទៅឱ្យមន្ត្រីនានា រួមមានលោក ហ៊ុន សែន និងលោក ជា ស៊ីម ដែលជាមនុស្សសំខាន់នៅក្នុងបក្ស។

មន្ត្រីផ្សេងៗនៅក្នុងក្រសួងការបរទេស និងក្រសួងការពារជាតិ ព្រមទាំងលោក ធន សារ៉ាយ ប្រធានអង្គការអាដហុកបច្ចុប្បន្នដែលនៅពេលនោះបានដឹកនាំស្ថាប័នស្រាវជ្រាវមួយពាក់ព័ន្ធនឹងគណបក្សកុម្មុយនីស្ត ដែលគេស្គាល់ថា ជាវិទ្យាស្ថានសង្គមវិទ្យា ក៏បានជាប់ពន្ធនាគារផងដែរ ហើយការដកហូតក៏បានចាប់ផ្តើមឡើងធ្វើឱ្យមានការដោះដូររដ្ឋមន្ត្រីមួយចំនួន។

លោក ហ្គុតថេសមែន បានសរសេរថា "វិទ្យាស្ថានសង្គមវិទ្យាបិទទ្វារដោយសារការឃុំខ្លួនលោក ធន សារ៉ាយ។ លោក ខៀវ កាញារីទ្ធ និពន្ធនាយកដែលមិនសូវសេរីរបស់កាសែតប្រចាំសប្តាហ៍កម្ពុជា និងសព្វថ្ងៃនេះជារដ្ឋមន្ត្រីក្រសួងព័ត៌មានក៏ត្រូវបានដកចេញពីតួនាទីរបស់លោកមួយរយៈពេលខ្លីដែរ។ ការពិភាក្សាដែលបានធ្វើឡើងអំពីកំណែទម្រង់នយោបាយកាន់តែមានការសម្ងាត់ថែមទៀត"។ តទៅទំព័រទី ២១

KhmerPost USA, LLC
សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us
តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA
ផ្សាយពាណិជ្ជកម្ម Advertising
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us
អ្នកនិពន្ធ Editorials
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us
អ្នកនិពន្ធកិត្តិយស Contributed Writers:
Kim Phien, Richard Howe,Jr.
ច្នៃសោភ័ណភាពកាសែត Design Artist
Heng Chhunleng
ជំនួយការរដ្ឋបាល Intern
Moniphal Bing

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at 100.00 or 120 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009



តមកពីទំព័រ ២០

## គណបក្សសង្គ្រោះជាតិមានគម្រោងធ្វើ...

ដោយមានការប្រឈមនៅពេលក្រោយមកជាមួយនឹងអំណាចរបស់គណបក្សប្រជាជនកម្ពុជា សកម្មភាពទាំងនោះត្រូវបានអនុញ្ញាតឱ្យបង្កើតឡើងដោយចំហ ហើយក្រោយមកត្រូវបានកែប្រែវិញ។

លោក ខាលីល ថាយ័រ អ្នកជំនាញផ្នែកអាស៊ីអាគ្នេយ៍នៅបណ្ឌិតសភាកងកម្លាំងការពារជាតិអូស្ត្រាលីបាននិយាយថា ការជៀសវាងពីប្រតិកម្មភ្លាមៗបែបនេះ គឺជាទង្វើមានតុល្យភាពសម្រាប់លោក សម រង្ស៊ី នៅពេលលោកព្យាយាមបង្កើនកម្លាំងគណបក្សប្រឆាំងរបស់លោក បន្ទាប់ពីមានកិច្ចព្រមព្រៀងដោយប្រុងប្រយ័ត្នជាមួយលោក ហ៊ុន សែន កាលពីថ្ងៃទី២២ ខែកក្កដា។

លោក ថាយ័រ ក៏បាននិយាយថា "យើងត្រូវពិនិត្យមើលអ្វីដែលគេបានអនុវត្ត ព្រោះកាលពីអតីតកាលកិច្ចព្រមព្រៀងបែបនេះមិនមានប្រយោជន៍ទេ។នៅពេលដែលគណបក្សប្រឆាំងបានធ្វើអ្វីមួយរដ្ឋាភិបាល ជាពិសេសលោក ហ៊ុន សែន មិនចូលចិត្តឡើយ"។

លោកបាននិយាយថា ភារកិច្ចធំបំផុតរបស់លោក សម រង្ស៊ី គឺបន្តបង្កើនការគាំទ្រលោក និងធ្វើជាគណបក្សប្រឆាំងក្នុងសភា ហើយលោក ហ៊ុន សែន ពិតជាមិនចូលចិត្តគណបក្សសង្គ្រោះជាតិទេនៅពេលការបោះឆ្នោតឆ្នាំ២០១៨ជិតចូលមកដល់។

លោកបាននិយាយថា "បញ្ហាប្រឈម គឺការបង្កើនការគាំទ្របន្តិចម្តងៗ និងធ្វើឱ្យលោក ហ៊ុន សែន ចូលរួមនៅក្នុងសភាបន្តិចម្តងៗ។ ប្រសិនបើលោកទទួលយកវាជាកេរ្តិ៍ដំណែលសម្រាប់កម្ពុជាដែលនឹងមានរយៈពេលយូរទៀតបន្ទាប់ពីរូបលោកទៅ"។

ទោះជាយ៉ាងណា លោក ដេវីដ ឆានល័រ ប្រវត្តិវិទូអំពីកម្ពុជាដ៏ឆ្នើមនេះបាននិយាយថា លោកគិតថា លោក សម រង្ស៊ី ទំនងជាមិនមានសំណាងជាងឪពុករបស់លោកក្នុងការបង្កើតគំនិតអំពីគណបក្សប្រឆាំងស្មោះត្រង់នេះទេ។

លោក ឆានល័រ បានសរសេរតាមអ៊ីម៉ែលថា ចំពោះខ្ញុំវាហាក់ដូចជានៅក្រៅព្រំដែននៃកិច្ចពិភាក្សានយោបាយកម្ពុជា ប៉ុន្តែការទទួលយកអាសនៈរបស់សមាជិកគណបក្សប្រឆាំងទាំង៥៥រូប បន្ទាប់ពីមិនចូលធ្វើការអស់រយៈពេលមួយឆ្នាំ គឺជាសញ្ញាល្អដែលមានតុល្យភាព"។

លោកបានលើកឡើងថា "មិនមានរឿងបែបនេះនៅអាមេរិក ឬបារាំងទេ ហើយរដ្ឋធម្មនុញ្ញរបស់កម្ពុជាក៏មិនយកគំរូតាមរដ្ឋធម្មនុញ្ញអង់គ្លេសដែរ។ គេពិតជាចង់ឃើញអ្វីដែលលោក ហ៊ុន សែន ធ្វើជាមួយសមាជិកគណបក្សប្រឆាំង"៕

**គីម ហឿន**

Continued from page 13

## CNRP's Plans in Opposition Break ...

party-aligned research body known as the Institute of Sociology, were also jailed and a purge began that saw ministers replaced.

"The Institute of Sociology closed with the detention of Thun Saray," Mr. Gottesman wrote. "Khieu Kanharith, the moderately liberal editor of the weekly Kampuchea [and now information minister], was briefly removed from his position. Whatever discussions had been taking place on political reform went even further underground."

As with later challenges to the CPP's power, the activities were allowed to develop openly and were then promptly quashed.

Carlyle Thayer, a Southeast Asia expert at the Australian Defense Force Academy, said that avoiding such a sudden backlash would be a balancing act for Mr. Rainsy as he seeks to build his opposition after the precarious deal he cut with Mr. Hun Sen on July 22.

"We have to see what is implemented as in the past these deals have run afoul when the opposition has done something the government, or particularly Hun Sen, does not like," Mr. Thayer said.

Mr. Thayer said Mr. Rainsy's biggest task will be continuing to build his base and operating as a parliamentary opposition as Mr. Hun Sen inevitably sours on the CNRP as the 2018 general election approaches.

"The challenge will be to build up his constituency over time and engage Hun Sen in the parliament over time. If he accepts it, it's a legacy for Cambodia that will endure long beyond him," he said.

However, David Chandler, the pre-eminent Cambodia historian, said he thinks it unlikely that Mr. Rainsy will have any more luck than his father did 50 years ago in cementing the idea of loyal opposition.

"It seems to me outside the boundaries of Cambodian political discourse, but seating the 55 opposition members, after their year in limbo, is on balance a hopeful sign," Mr. Chandler said in an email.

"There's no such thing in the U.S. or France, and Cambodia's Constitution is not modeled on the U.K.'s," he said. "It will be intriguing to see what Hun Sen does with the opposition members."

GREATER LOWELL
CHAMBER OF COMMERCE

131 Merrimack Street – Lowell MA
978-459-8154
www.greaterlowellchamber.org

**A resource for your business or organization!**
- Networking Events
- Seminars
- Resources
- TV & Radio Shows
- And more!

**សភាពាណិជ្ជកម្មនៅក្រុងឡូវែល គឺជាធនធានមួយសម្រាប់មុខរបរ ឬសម្រាប់អង្គការរបស់លោកអ្នក**
- ព្រឹត្តិការណ៍ទំនាក់ទំនង
- សន្និសីទ
- រកធនធាន
- កម្មវិធីទូរទស្សន៍ និងវិទ្យុ
- និងនៅមានច្រើនទៀត

**នៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៤ និងមានតាំងពិពណ៌ពាណិជ្ជកម្ម និងបង្ហាញផលិតផលនៅសណ្ឋាគារ រ៉េឌីសាន់ នៅឆែមហ្វត។**

**Save the Date: Business Expo & Showcase on October 28th at the Radisson Hotel & Suites in Chelmsford.**

ខូម័រ សិប្បកម្មច្នៃរបស់ណាកក្រានីត
COLMER MONUMENT WORKS

Memorials of Distinction
អាស័យដ្ឋាន:1025 Lawrence Street Lowell, MA 01852-4898
(978) 452-7821



- Granite Memorials — ផ្នូររាងបញ្ឈរធ្វើពីថ្មក្រានីត
- Granite & Bronze Markers — ផ្នូរផ្តេកមានឆ្លាក់សរិទ្ធលេថ្មក្រានីត
- Cemetery Lettering in Khmer — មានឆ្លាក់អក្សរខ្មែរលើថ្មនៃផ្នូរ

COLMER Monument Works

ភាពថ្លៃថ្នូរ កិត្តិយស និងការគោរពជូនលោកអ្នក
Honor. Dignity. Respect for All

## ត្រូវលក់ហាងធ្វើក្រចក (Liberty Nail)
## Help Wanted រកបុគ្គលិកស្រីធ្វើក្រចក

ត្រូវលក់ហាងក្រចក Liberty Nail នៅ Dracut ក្នុង Walbrook Plaza

**មានកន្លែងចតឡាន**

អាស័យដ្ឋានហាង : 18 Pleasant St, Dracut, MA 01826

-មានតុធ្វើក្រចកដៃ ៤ (ថ្មី) -តុធ្វើក្រចកជើង ៣ (ថ្មី) -សំបូរអតិជនចេញចូលច្រើន

-ហាងធំទូលាយអាចដាក់សម្ភារៈកែសម្ផស្ស ឬធ្វើជាបន្ទប់ Waxing បាន

**ត្រូវការជ្រើសរើសបុគ្គលិកស្រីធ្វើក្រចកប្រញាប់ៈ**

-ត្រូវចេះធ្វើក្រចកដៃ និងជើងៈ ទាំងម្សៅ និងធម្មតា

-ត្រូវមានបទពិសោធន៍ និងសញ្ញាប័ត្រធ្វើក្រចក

Spacious facility, may add waxing room

Brand new mani & pedi equipment installed

Help wanted nail technician with liscence and experience mani & pedi

សូមទូរស័ព្ទមក លីសា **(Lisa) 978-895-2083**

## ប្រូវីដិនខ្មែរវីដេអូ

មានជួសជុល និងលក់កុន

ចិន-ថៃ-ខ្មែរ-ឥណ្ឌា

គ្រប់ប្រភេទមានចម្រៀងសម័យវីដេអូ

ខារ៉ាអូខេថ្មីៗ

742 Potters Avenue

Providence, RI 02907

ទូរស័ព្ទ : (401) 787 6663

## សិក្សាពីឥស្លាម

**សួរ :** មានចម្ងល់អ្វីទេពីឥស្លាម?

**ឆ្លើយ :** សូមទៅមើលគេហទំព័រ

www.peacetv.tv ឬគេហទំព័រ

មួយទៀត www.gainpeace.com.

Q) Any Questions on Islam?

A)watch www.peacetv.tv

visit www.gainpeace.com.

## សារព័ត៌មានខ្មែរប៉ុស ស.រ.អា ឡូវែល រដ្ឋម៉ាសាឈូសេត
### ដំណឹងជ្រើសរើសបុគ្គលិក

តួនាទី : ជំនួយការនិពន្ធនាយក

**បេក្ខជនត្រូវៈ**

-មានបរិញ្ញាប័ត្រពីប្រទេសខ្មែរ

-ជាមនុស្សដែលចេះសម្របខ្លួនក្នុងការងារ និងមជ្ឈដ្ឋានខាងក្រៅ

-ចេះវាយអត្ថបទជាភាសាខ្មែរ និងអង់គ្លេស

-មានបទពិសោធន៍ធ្វើការផ្នែកសង្គម ពីបី ទៅប្រាំឆ្នាំ

-ចេះធ្វើការជាក្រុម

-មានស្មារតីចង់ចេះ និងដឹង ដើម្បីភាពរីកចម្រើននៃការងារ

-មានពេលវេលាបត់បែនសម្រាប់ការងារក្នុងពេលចាំបាច់ (ពេលល្ងាច និងចុងសប្តាហ៍)

បេក្ខជនចាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេប(CV) និង Cover Letter

មកកាន់អាស័យដ្ឋាន

**45 Merrimack Street. Suite 218A**

**Lowell, MA 01852 ឬតាមអ៊ីម៉ែល khmerpostusa@gmail.com**

